Formation, Dialogue, Cooperation

# អ្នកនាំសារ
## The Messenger

កាសែតចេញផ្សាយប្រចាំខែ ឆ្នាំទី៤ ថ្ងៃទី០១-៣១ ខែសីហា ឆ្នាំ២០១១ លក់តម្លៃ ១០០០រៀល តែប៉ុណ្ណោះ លេខ ៤៨

## មាតិកា



អ្នកជំនាញស្នើឱ្យយុវជនប្រើ... ទំព័រ ៥



សិប្បករ: ឧបសគ្គសម្រាប់សិប្បកម្ម ទំព័រ ៩



ល្ខោនបាសាក់កំពុងមានប្រជាប្រិយភាព ទំព័រ ១៧

# កម្ពុជាទទួលកម្ចី ៥០០លានដុល្លារ ពីធនាគារ អេឌីប៊ីសម្រាប់អភិវឌ្ឍន៍ពីឆ្នាំ២០១១_២០១៣



ការខ្ចីលុយបរទេស ឬស្ថាប័នហិរញ្ញវត្ថុធំៗ ដូចជាធនាគារពិភពលោក មូលនិធិរូបិយវត្ថុអន្តរជាតិ ឬធនាគារអភិវឌ្ឍន៍អាស៊ី (អេឌីប៊ី)យកមកកសាងហេដ្ឋារចនាសម្ព័ន្ធផ្សេងៗក្នុងការជំរុញកំណើនសេដ្ឋកិច្ចដើម្បីអភិវឌ្ឍប្រទេស ជាការងារដែលមិនអាចខ្វះបាន។ ប៉ុន្តែការដែលរដ្ឋាភិបាលប្រើប្រាស់ប្រាក់នោះ ឱ្យមានតម្លាភាព គណនេយ្យភាព និងប្រសិទ្ធភាពខ្ពស់ គឺជាអ្វីដែលរឹតតែសំខាន់ទៅទៀត។ ទំព័រទី១០_១១

កម្មវិធីវិទ្យុ

**អេម៉ានូអែល** សំឡេងពីព្រះសហគមន៍កាតូលិក !

ភ្នំពេញ : FM 102.5 Mhz ម៉ោង២:០០-៣:០០ រាល់រសៀលថ្ងៃសុក្រ
បាត់ដំបង : FM 91.0 Mhz ម៉ោង ៧:៣០-៨:៣០ រាល់យប់ថ្ងៃសៅរ៍
សៀមរាប: FM 102.5 Mhz ១០:០០-១១:០០ រាល់ថ្ងៃសៅរ៍
កំពង់ធំ : FM 88.5 Mhz ម៉ោង ១២:៣០-១:៣០ ថ្ងៃសៅរ៍ថ្ងៃត្រង់
កំពង់ចាម : FM 100.5 Mhz ម៉ោង ៦:៣០-៧:០០ យប់ថ្ងៃអាទិត្យ
ក្រុងព្រះសីហនុ : FM 107.5 Mhz ម៉ោង៥:០០-៦:០០ រសៀលថ្ងៃសៅរ៍
កំពត : FM 93.25 Mhz ម៉ោង ៥:០០-៦:០០ រសៀលថ្ងៃសៅរ៍

# រូបភាពប្រចាំខែ



Photo : V. Sambath

ទោះបីមានការហាមឃាត់ពីច្បាប់ចរាចរណ៍ផ្លូវគោកនៃព្រះរាជាណាចក្រកម្ពុជា ប៉ុន្តែការជិះនៅលើដំបូលរថយន្តនៅតែមាន។



Photo : V. Sambath

ការដឹកច្រើនហួសបែបនេះ និងជិះលើបែបនេះ ជាការសំចៃថវិកា ប៉ុន្តែនេះ មិនមែនជាការសំចៃជីវិតទេ។ នៅពេលដែលមានការគ្រោះថ្នាក់ ទោះបីគាត់សោកស្ដាយក៏ហួសពេលដែរ។



Photo : Hong Menea

គណបក្សសមរង្ស៊ីបានផ្លាស់ប្ដូរទីស្នាក់ការកណ្ដាលរបស់ខ្លួនទៅកាន់ទីកន្លែងថ្មី នៅសង្កាត់ចាក់អង្រែលើ ខណ្ឌមានជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៣ កក្កដា។



Photo : Hong Menea

ការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ(បាក់ឌុប) សម្រាប់ឆ្នាំសិក្សា២០១០-២០១១ បានចាប់ផ្ដើមកាលពីថ្ងៃទី២៥ កក្កដា ដែលមានបេក្ខជនចូលរួមប្រឡងនៅទូទាំងប្រទេសសរុប ១១៣,៧៩៥នាក់។



Photo : Narong

ប្រជាពលរដ្ឋនៅតំបន់បឹងកក់ រាជធានីភ្នំពេញជាង ១០០០គ្រួសារកំពុងបែកចេញជាពីរក្រុម។ មួយក្រុមទាមទារឲ្យរដ្ឋាភិបាលផ្ដល់សំណង់ជូនគេអភិវឌ្ឍនៅនឹងកន្លែង និងមួយក្រុមទាមទារតាមការបង្ហាញរបស់អាជ្ញាធររាជធានីភ្នំពេញ។

# គ្រោះថ្នាក់ចរាចរណ៍ កើតឡើងគួរឱ្យព្រួយបារម្ភណ៍



លោកលី សុវណ្ណា ប្រធានការិយាល័យផ្សព្វផ្សាយព័ត៌មានព្រះសហគមន៍កាតូលិក (CSC)

បើតាមការសង្កេតចាប់ពីដើមខែកក្កដា រហូតមកដល់ដើមខែសីហានេះ យើងឃើញថា គ្រោះថ្នាក់ចរាចរណ៍ធំៗ នៅលើផ្លូវជាតិនៃព្រះរាជាណាចក្រកម្ពុជា កើតឡើងយ៉ាងគួរឱ្យព្រួយបារម្ភណ៍។ គ្រោះថ្នាក់ទាំងនេះ បានបណ្តាលឱ្យមនុស្សរងរបួស និងស្លាប់ជាច្រើននាក់។ តើបញ្ហាទាំងនេះបណ្តាលមកពីអ្វី? តើទាំងអស់គ្នាចូលរួមដើម្បីកាត់បន្ថយគ្រោះថ្នាក់ទាំងអស់នេះយ៉ាងដូចម្តេច?

បើយោងតាមការចុះផ្សាយលើទំព័រសារព័ត៌មាន ក្នុងស្រុកនានា សមត្ថកិច្ចបានអះអាង គ្រោះថ្នាក់កើតឡើង ដោយសារការបើកបរហួសល្បឿនកំណត់ ការស្រវឹង ការមិនគោរពសិទ្ធិអាទិភាព ការប្រជែង ការដែលអ្នកបើកបរមិនប្រកាន់ស្តាំ ការមិនគោរពភ្លើងសញ្ញា ព្រមទាំងកត្តាយានយន្ត និងកត្តាសុខភាពអ្នកបើកបរជាដើម។

ប្រមុខរាជរដ្ឋាភិបាលតែងអំពាវនាវឱ្យពលរដ្ឋទាំងអស់នាំគ្នាគោរពច្បាប់ចរាចរណ៍ដើម្បីកាត់បន្ថយនូវគ្រោះថ្នាក់។

ប្រជាពលរដ្ឋហាក់ដូចជា ពុំទាន់យល់ដឹងល្អមពីច្បាប់ចរាចរណ៍នៅឡើយ។ តើអាជ្ញាធរមានសមត្ថកិច្ចបានអប់រំផ្សព្វផ្សាយល្អមហើយឬនៅ?

ប្រជាពលរដ្ឋខ្លះតែងរអ៊ូពីការផាកពិន័យរបស់ប៉ូលីសចរាចរណ៍មួយចំនួន ដែលរកចាប់តែកំហុសគាត់ ដោយមិនបានធ្វើការអប់រំប្រជាពលរដ្ឋ ឱ្យយល់ដឹងអំពីច្បាប់ចរាចរណ៍ឱ្យទូលំទូលាយនៅឡើយ។ អ្នកបើកបរក៏ដូចគ្នា ពេលខ្លះគាត់មិនចាប់អារម្មណ៍នឹងគោរពភ្លើង ឬស្លាកសញ្ញាចរាចរណ៍ឡើយ គឺសម្លឹងរកប៉ូលីសមានន័យថា គាត់ខ្លាចតែប៉ូលីសផាកពិន័យប៉ុណ្ណោះ។

គ្រោះថ្នាក់ម្តងៗ ច្រើនតែមានអ្នកបាត់បង់ជីវិត ឬរបួសធ្ងន់ទៅជាពិការ មិនអាចប្រកបរបរចិញ្ចឹមជីវិតបាន។ តួយ៉ាងគ្រាន់តែ ៦ខែដើមឆ្នាំ២០១១ មានគ្រោះថ្នាក់ចរាចរណ៍ចំនួន ២៩៤៥ករណី ដែលបណ្តាលឱ្យមានអ្នកស្លាប់ចំនួន ១១០០នាក់។

តើយើងត្រូវនាំគ្នាគោរពច្បាប់ចរាចរណ៍ ឬត្រូវគោរពប៉ូលីសដើម្បីការពារជីវិតរបស់ខ្លួន? តើការផាកពិន័យធ្ងន់ធ្ងរ គឺពិតជាជួយកាត់បន្ថយគ្រោះថ្នាក់ចរាចរណ៍មែនឬ? បើម្នាក់ៗ បើកបរមិនយល់ពីសីលធម៌ និងមិនយល់ពីច្បាប់ចរាចរណ៍នោះ?

ការិយាល័យផ្សព្វផ្សាយព័ត៌មានកាតូលិក CSC មានផលិតផលថ្មី គឺ CD Vol.14 ដែលមានចម្រៀងចំនួន ១២បទ។
ចម្រៀងទាំងនេះអធិប្បាយអំពីការគោរពសរសើរព្រះជាម្ចាស់។
CD Vol.14 នេះមានតម្លៃត្រឹមតែ ១.៥០ ដុល្លារ ≈ ៦០០០ រៀល។

## សេចក្តីជូនដំណឹង

កម្មវិធីវិទ្យុ ខ្ញុំត្រូវការអ្នក នៃការិយាល័យផ្សព្វផ្សាយព័ត៌មានព្រះសហគមន៍រៀបចំការប្រឡង និពន្ធអត្ថបទល្ខោននិយាយ និងអត្ថបទចម្រៀង។

លក្ខខណ្ឌ : ១- បេក្ខជន-នារីត្រូវមានអាយុ ១៥ឆ្នាំឡើង។ ២-អត្ថបទល្ខោននិយាយ និងចម្រៀងត្រូវមានខ្លឹមសារអប់រំយុវវ័យលើបញ្ហា ជាក់ស្តែងក្នុងសង្គមដូចជា ការសិក្សា ការកំសាន្ត ស្នេហា...។ ៣-អត្ថបទល្ខោននិយាយនិពន្ធពី១២ ទៅ១០០ទំព័រ។ ៤-អត្ថបទចម្រៀង ត្រូវមានទំនុកច្រៀងភ្ជាប់។

ព័តមានបន្ថែម : ០៩២ ៧៤០ ០០២/០៩៧ ៩៣០ ៩៨៩០ ឬអ៊ីមែល vccradio@gmail.com អរគុណ!



## ជ្រើសរើសបុគ្គលិក ជួយគាំទ្រយុវជន
## សម្រាប់បេសកកម្មចំពោះពលករ ក្នុងភូមិភាគភ្នំពេញ

អាយុលើស ២៥ឆ្នាំ នៅលីវ ឬមានគ្រួសារ

**តួនាទី**

-បង្កើតឱ្យរីកចម្រើន និងជួយណែនាំក្រុមយុវពលករ
-ជួយឱ្យមានសកម្មភាពផ្សេងៗ ត្រូវបានបង្កើតជាមួយយុវជន និងដោយយុវជន
-ធ្វើការងារការិយាល័យផង ជួបនៅកន្លែងយុវជន ដែលទាក់ទងជាមួយគណៈកម្មការពលករផង

**សមត្ថភាព**

-ចេះយកចិត្តទុកដាក់ក្នុងការស្តាប់
-ចេះរិះគិតពិចារណា
-ចេះសួរសំនួរ និងជួយឱ្យគេឆ្លើយ
-ជួយណែនាំក្រុមយុវជន និងយុវនារី ដោយមិនសម្រេចជំនួសគេ
-សម្របសម្រួលក្រុមអ្នកជួយគាំទ្រផ្សេងៗ
-ចេះលើកតម្លៃរបស់យុវជន

**លក្ខណៈការងារ**

-ម៉ោងការងារមិនទៀងទាត់
-អាចធ្វើការនៅថ្ងៃអាទិត្យ
-ទទួលការបណ្តុះបណ្តាលដើម្បីធ្វើជាអ្នកអប់រំ
-រៀបចំសកម្មភាពជាមួយយុវជននៅតាមខេត្ត
-ជិះយានយន្តទៅជួបយុវជននៅទីតាំងគេ
-ធ្វើការរិះគិតតាមក្រោយយ៉ាងញឹកញាប់ជាមួយ និងសមាជិកគណៈកម្មការពលករ

**លក្ខណៈកិច្ចសន្យាការងារ**

-លក្ខន្តិកៈភូមិភាគកាតូលិកភ្នំពេញ
-កិច្ចសន្យាបុគ្គលិកពេញសិទ្ធ ការសាកល្បងរយៈពេលចំនួន ៣ខែ
-កិច្ចសន្យាថ្មីបន្តរៀងរាល់ ពីរឆ្នាំ
-អាចធ្វើការកន្លះថ្ងៃបាន
-ការិយាល័យនៅផ្ទះភូមិភាគភ្នំពេញ ខណ្ឌចំការមន សង្កាត់បឹងត្របែក ផ្លូវ ៤៧៤។

CV ផ្ញើ ទៅ 9@defondyann.com

# សេដ្ឋកិច្ច

## ផលិតផលកសិកម្មនាំចេញកើនដល់ ១៣៩លានដុល្លារ

**ខាន់ ភីរម្យ**



Photo : S. Philong

ការនាំចេញផលិលផលកសិកម្ម និងកៃច្នៃរបស់កម្ពុជា រយៈពេល៦ខែ ដើមឆ្នាំ២០១១នេះ ទទួលបានកំណើនរហូតទៅដល់ ១៣៩លាន ដុល្លារ ។

តួលេខពីក្រសួងពាណិជ្ជកម្មបានបង្ហាញថា ក្នុងរង្វង់ឆមាសទី១ ដើមឆ្នាំ២០១១ នេះ ការនាំចេញផលិតផលកសិកម្មរបស់ប្រទេសកម្ពុជាទៅកាន់ទីផ្សារបរទេស មានការកើនឡើងពី ៧០,៧៧លាន-ដុល្លារ គឺចាប់ពីឆមាសទី១ដើមឆ្នាំ២០១០ ទៅដល់ ២១០លានដុល្លារ ។ បើផ្អែកតាមតួលេខនេះ ការនាំចេញផលិតផលកសិកម្មរបស់កម្ពុជាទៅកាន់ទីផ្សារអន្តរជាតិមានកំណើនជាង ១៣៩ លានដុល្លារ ។

ប្រភពដដែលនេះបានឱ្យដឹងថា ផលិតផលកសិ-កម្មដែលកម្ពុជានាំចេញទៅទីផ្សារបរទេសក្នុងមួយឆមាសនេះ មានចំនួនប្រមាណ១៦មុខ ខណៈដែលកាលពីរយៈពេលដូចគ្នានៅឆ្នាំ២០១០ ការនាំចេញមានត្រឹមតែ១៣មុខតែប៉ុណ្ណោះ ។ ផលិតផលដែលប្លែក និងត្រូវបានកត់ត្រាដោយក្រសួងពាណិជ្ជកម្មនោះ គឺមានស្រូវ សណ្តែកដី និងកាហ្វេ ។

បើតាមមន្ត្រីក្រសួងពាណិជ្ជកម្មមួយរូប បានឱ្យដឹងថា សណ្តែកដី និងកាហ្វេ គឺជាផលិតផលកសិ-កម្មថ្មី ដែលកម្ពុជានាំចេញក្នុងរយៈពេល ៦ខែដើមឆ្នាំនេះមិនមែនស្រូវនោះទេ ។ តាមពិតការនាំចេញស្រូវមានច្រើន ពិសេស គឺទៅកាន់ប្រទេសជិតខាងគ្រាន់តែមិនមានតួលេខច្បាស់លាស់ ។ ការនាំចេញស្រូវភាគច្រើន ធ្វើឡើងដោយប្រជាពលរដ្ឋផ្ទាល់ ។ ផលិតផលកសិកម្មដែលកម្ពុជានាំចេញទៅកាន់ទីផ្សារក្រៅប្រទេសក្នុងឆមាសទី១ ដើមឆ្នាំកន្លងទៅនេះ រួមមានសត្វរស់ ផលិតផលនេសាទស្រស់ និងកៃច្នៃ ដំឡូងមីស្រស់ ឬកៃច្នៃ អង្ករ ស្រូវ ពោត សណ្តែកសៀង សណ្តែកដី គ្រាប់កាហ្វេ ល្ង ម្រេច គ្រាប់ស្វាយចន្ទី កៅស៊ូក្រែប ឈើកៃច្នៃ គ្រឿងសង្ហារិម និងផលិតផលកសិកម្មផ្សេងៗទៀត ។

តួលេខក្រសួងពាណិជ្ជកម្ម ក៏បានបង្ហាញថា ក្នុងចំណោមផលិតផលដែលកម្ពុជា បាននាំចេញ រយៈពេល៦ខែដើមឆ្នាំនេះ ផលិតផលដែលលេចធ្លោ រួមមាន កៅស៊ូក្រែប អង្ករ និងផលិតផលដំឡូងមី ។

**ផលិតផលកសិកម្មនាំចេញលេចធ្លោនាដើមឆ្នាំ២០១១**

ប្រភពពីក្រសួងពាណិជ្ជកម្ម បានឱ្យដឹងថា រយៈពេល ៦ខែ ដើមឆ្នាំនេះ កម្ពុជាបាននាំចេញផលិតផលកៅស៊ូក្រែបមានបរិមាណរហូតដល់ទៅ ២១៥០០តោន ដែលគិតជាទឹកប្រាក់មានរហូតដល់ទៅជាង ១០២លានដុល្លារ។ ផលិតផលអង្ករដែលកម្ពុជាបាននាំចេញទៅនោះ គឺមានបរិមាណចំនួន ៨០៤៤២តោន ដែលគិតជាទឹកប្រាក់ចំនួន ៤៥.៦លានដុល្លារ។ ដោយឡែក ដំឡូងមីវិញ បរិមាណនៃការនាំចេញមានរហូតដល់ទៅ ២១២០១៨តោន ដែលគិតជាទឹកប្រាក់នាំចេញ គឺមានចំនួនរហូតដល់ទៅ ៨,៧លានដុល្លារ។

ប្រភពដដែលក៏បញ្ជាក់ថា បើប្រៀបធៀបទៅកាលពីឆមាសទី១ ក្នុងឆ្នាំ២០១០ ការនាំចេញកៅ-ស៊ូក្រែប គឺមានបរិមាណត្រឹមតែ ១១,៦៦៥ តោន គិតជាទឹកប្រាក់ មានតម្លៃប្រមាណត្រឹមតែ ៣០,៥ លានដុល្លារ តែប៉ុណ្ណោះ ។ បរិមាណនៃការនាំចេញអង្ករ គឺមានចំនួនត្រឹមតែ ១០៧,២៩១តោន ដែលមានទឹកប្រាក់តម្លៃ ត្រឹមជាង ១៣,៤លានដុល្លារ ។ ចំណែក ដំឡូងមីវិញ ការនាំចេញបាន ១១៣០៦៨ តោន ដែលគិតជាទឹកប្រាក់ គឺ ២,៨លានដុល្លារ ។

# សុខភាព

## ការពិសាស្រាផ្តល់ទុក្ខទោសសម្រាប់សុខភាពជាងការផ្តល់ផលចំណេញ

**ជាត សំភី**



Photo : C. Lang

ស្រាជាភេសជ្ជៈមួយប្រភេទដែលមនុស្សច្រើននិយមចូលចិត្ត ។ ប៉ុន្តែការពិសានូវគ្រឿងស្រវឹងនេះហួសហេតុ នឹងផ្តល់ផលប៉ះពាល់យ៉ាងខ្លាំងក្លា ដល់សុខភាពរបស់យើង ។

លោកវេជ្ជបណ្ឌិតឈៀ គន្ធារី នៅឯមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត រាជធានីភ្នំពេញ មានប្រសា-សន៍ថា ជាតិពុលនៅក្នុងស្រាគឺអេតាណុល ។ លោកវេជ្ជបណ្ឌិតបន្តថា ការផឹកស្រាច្រើនធ្វើឱ្យមានជាតិពុលក្នុងខ្លួន ឬស្រវឹង ។ នៅពេលស្រវឹង គាត់ទន់ដៃទន់ជើង ឬធ្វើចលនាពុំប្រក្រតី ។ គាត់អាចនិយាយផ្តេសផ្តាស រវើយរវាយស្រមើលស្រមៃ ខុសធម្មតា ឬរហូតដល់សន្លប់បាត់ស្មារតីទៀតផង ។

លោកវេជ្ជបណ្ឌិត បន្ថែមថា លើសពីនេះស្រាជាមូលហេតុរួមផ្សំនៃជំងឺជាច្រើនប្រភេទ ដូចជា ជំងឺលើសឈាម ទឹកនោមផ្អែម រលាកថ្លើមរ៉ាំរ៉ៃ រលាកស្រោមខួរ ឬជំងឺរលាកនៅតម្រោងនោមជាដើម ។ ដូច្នេះអ្នកដែលផឹកស្រានឹងប្រឈមមុខកាន់តែខ្ពស់ចំពោះជំងឺទាំងនេះ ។ ហើយសម្រាប់អ្នកដែលកើតហើយនោះ សភាពជំងឺកាន់តែដុនដាបថែមទៀត ។

ម្យ៉ាងវិញទៀតសម្រាប់អ្នកដែលផឹកស្រាយូររហូតដល់ញៀនដែលយើងតែងតែហៅថា "ដុះមេ" ហើយនោះ នៅពេលដែលគាត់បញ្ឈប់ភ្លាម គាត់ក៏មានបញ្ហាផងដែរដូចជា បញ្ហាសរសៃប្រសាទ ញ័រដៃញ័រជើង គេងមិនលក់ បាយមិនឆ្ងាញ់ និងថប់ៗដង្ហើម-ល- ។ ដូច្នេះបើគាត់ចង់ផ្តាច់គាត់គួរតែទៅរកគ្រូពេទ្យឱ្យព្យាបាល និងប្រើថ្នាំបានត្រឹមត្រូវ ។

លោកវេជ្ជបណ្ឌិត បញ្ជាក់ថា ជាការល្អ បើយើងមិនទាន់ចេះផឹកស្រា យើងគួរកុំផឹក ។ បើយើងផឹកច្រើនយើងគួរតែបន្ថយបន្តិចម្តងៗ ពីព្រោះស្រាមិនត្រឹមតែប៉ះពាល់ដល់សុខភាព ថែមទាំងធ្វើឱ្យយើងគ្រោះថ្នាក់ពេលបើកបរដោយសារការស្រវឹង ។

# អ្នកជំនាញស្នើឱ្យយុវជនប្រើប្រាស់សម្ភារៈ និងបច្ចេកវិទ្យាឱ្យចំគោលដៅ

**ខាន់ ភីរម្យ**

លោកព្រាប កុល ឯកអគ្គរាជទូតសន្តិភាព មានប្រសាសន៍ថា ក្នុងយុគសម័យដែលប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន មានការរីកចម្រើនខ្លាំងនោះ យុវជនគួរតែប្រើប្រាស់ឧបករណ៍បច្ចេកវិទ្យាទាំងនេះឱ្យបានចំគោលដៅត្រឹមត្រូវ ។

តាមការសង្កេតផ្ទាល់របស់លោកដែលធ្វើការជាមួយនិងយុវជន បានបង្ហាញថា ទន្ទឹមនឹងការរីកចម្រើននេះ មានយុវជនមួយចំនួនបានប្រើប្រាស់នូវឧបករណ៍ និងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានទាំងនោះខុសគោលដៅ ដែលវាអាចបណ្តាលឱ្យមាននូវវិបត្តិសម្រាប់ខ្លួន និងវិបត្តិដល់គ្រួសារផងដែរ ។

លោកព្រាប កុល ក៏ប្រាប់ឱ្យដឹងទៀតថា ដោយសារតែតម្លៃទូរស័ព្ទដៃ ស៊ីមកាត និងការហៅចេញមានតម្លៃថោក ព្រមទាំងប្រព័ន្ធអ៊ីនធឺណិត និងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានផ្សេងៗទៀត មានការបើកទូលាយ យុវជនមួយចំនួនបានកំពុងញៀនប្រើប្រាស់ឧបករណ៍ និងប្រព័ន្ធទាំងនោះ ដ៏ហួសកម្រិតរហូតដល់ធ្វើឱ្យពួកគេរងផលប៉ះពាល់ដល់សុខភាពមកពីការរំខាននិងរាំងស្ទះដល់ការសិក្សា ។ យុវជនខ្លះឈានដល់ការប្រើប្រាស់ឧបករណ៍ព័ត៌មានវិទ្យាទាំងនោះ នៅក្នុងគោលដៅអសកម្ម ដែលអាចនឹងគ្រោះថ្នាក់ចំពោះខ្លួនពួកគេផ្ទាល់ គ្រួសារ និងសង្គមផងដែរ ។ លោកព្រាប កុល បញ្ជាក់ថា : "សម្ភារៈបច្ចេកវិទ្យាព័ត៌មាន ជាអាវុធមុខពីរ ។ វាអាចជួយអ្នក តែវាក៏អាចសម្លាប់អ្នក ឬអាចបំផ្លាញអ្នកបានដែរ" ។ លោកបានបន្តទៀតថា ដើម្បីកុំឱ្យខ្លួនយើងក្លាយជាជនរងគ្រោះ ដោយសារសម្ភារៈទាំងនោះ យុវជនគប្បីត្រូវតែចេះប្រើប្រាស់វា ឱ្យទៅជាផលប្រយោជន៍ដល់ខ្លួន តាមវិធីស្របច្បាប់ ហើយត្រូវចេះលៃលកពេលវេលាប្រើប្រាស់ឱ្យត្រឹមត្រូវផង ។ លោកបន្ថែមថា : "ខ្ញុំមានហ្វេសបុក **(Facebook)** ដូចយុវជនដែរ ។ ប៉ុន្តែខ្ញុំឆ្លៀតប្រើប្រាស់វា តែពេលដែលទំនេរប៉ុណ្ណោះ ដើម្បីចែករំលែកបទពិសោធន៍ការងារ និងជីវិត ដល់មិត្តភក្តិដែលរាប់អានខ្ញុំដែលមានប្រមាណ១០000នាក់ ក្នុងគណនីរបស់ខ្ញុំ" ។

កាលពីពេលថ្មីៗកន្លងទៅនេះឯកឧត្តមសូរ ឃុន រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ បានឱ្យដឹងថា បើយោងទៅតាមតួលេខមកពីការលក់ស៊ីមកាត និងទូរស័ព្ទ ចំនួនទូរស័ព្ទចល័ត និងអចល័ត នៅប្រទេសកម្ពុជា មានសន្ទុះកើនឡើងរហូតដល់ ១៣លាន គ្រឿង ។ ឯកឧត្តមរដ្ឋមន្ត្រី ក៏ប្រាប់ឱ្យដឹងផងដែរថា នៅក្នុងចំណោមអ្នកដែលប្រើប្រាស់ទូរស័ព្ទចំនួន ១៣លានគ្រឿង ទូរស័ព្ទចល័តត្រូវបានប្រើចំនួនជាង ១២.៥ លានគ្រឿង ដែលវាមានអាត្រាស្មើនឹង ៩១គ្រឿង នៅក្នុងប្រជាជនចំនួន ១០0នាក់ ។ ចំណែកទូរស័ព្ទអចល័ត មានប្រើជិត 0.៥ លានគ្រឿង មានអាត្រាស្មើ ៣គ្រឿងនៅក្នុងចំណោមប្រជាជនចំនួន ១០0 នាក់ ។ម្យ៉ាងវិញទៀត ចំនួនអ្នកចុះឈ្មោះប្រើអ៊ីនធឺណិត មានប្រមាណជា 0.៦៨លាននាក់ ដែលមានអត្រាស្មើនឹង ៥% នៃចំនួនប្រជាជនជាង ១៤ លាននាក់នៅក្នុងប្រទេស ។

ជេន ផានីត អាយុ ១៤ឆ្នាំ យុវសិស្សនៅវិទ្យាល័យមួយ នៅក្នុងរាជធានីភ្នំពេញ អះអាងថា សព្វថ្ងៃនេះ គេប្រើប្រាស់ទូរស័ព្ទចំនួនពីរគ្រឿង ដោយមួយគ្រឿងសម្រាប់ទំនាក់ទំនងជាមួយនិងឪពុកម្តាយរបស់គេ ហើយមួយគ្រឿងទៀត គឺទាក់ទងជាមួយនិងមិត្តភក្តិរបស់គេ ។ ផានីត ក៏ប្រាប់ឱ្យដឹងថា ថ្វីត្បិតតែរូបគេមានទូរស័ព្ទពីរគ្រឿងមែន ប៉ុន្តែការប្រើប្រាស់ទូរស័ព្ទបែបនេះ គឺច្រើនតែប្រើ នៅពេលទំនេរ និងណាត់មិត្តភក្តិទៅរៀនតែប៉ុណ្ណោះ ។ ផានីត បញ្ជាក់ឱ្យដឹងដែរថា : "ខ្ញុំខល (Call-ហៅចេញ) តែនៅពេលទំនេរទេដូចជា ធ្វើការណាត់មិត្តភក្តិឱ្យមកយកទៅដើរលេង ឌុបទៅរៀន និងឱ្យម៉ាក់ និងប៉ា គាត់ងាយស្រួលរកខ្ញុំប៉ុណ្ណោះ" ។



Photo :S. Philong

## កសិកម្ម

# ទោះមានដីតូច ក៏អាចលើកស្ទួយជីវភាពបានដែរ

**ជាត សំភី**



Photo : DR

បើតាមប្រសាសន៍របស់អ្នកជំនាញ បានឱ្យដឹងថា ទោះបីជាកសិករមានដីតូច ឬត្រឹមតែ ២៥ម៉ែត្រការ៉េ ក៏គាត់អាចធ្វើការលើដីនោះ ដើម្បីចិញ្ចឹមជីវភាពបានដែរ ។

លោកគាម មករាឌី នាយកកម្មវិធីបរិស្ថាន និងសុខភាពនៃមជ្ឈមណ្ឌលសិក្សា និងអភិវឌ្ឍន៍កសិកម្មកម្ពុជា ហៅកាត់ថា សេដាក មានប្រសាសន៍ថា ទោះបីដីតូចៗ តែបើសិនកសិករព្យាយាម និងប្រើធនធានខ្លះ ដើម្បីធ្វើវិនិយោគលើដីនោះ គាត់អាចទទួលសារៈប្រយោជន៍មែន ។

លោកគាម មករាឌី បន្តថា នៅក្នុងដីក្បាលតូចៗនេះ កសិករមានជម្រើសច្រើន ក្នុងការប្រើប្រាស់ ។ គាត់អាចធ្វើជាសួនរង្វង់ ។ ក្នុងសួនរង្វង់នេះកសិករអាចដាំដំណាំបណ្តាក់គ្នាច្រើនប្រភេទ ដូចជា ដំណាំយកផ្លែមាន ត្រាវ ត្រប់ សណ្តែកគួរ បន្ទាប់មកគាត់អាចដាំជាដំណាំយកស្លឹកដូចជា ស្ពៃ ស្ពៃចង្កឹះ ស្ពៃស ឬស្ពៃក្រញាញ់-ល- ។ កសិករអាចជីកស្រះចិញ្ចឹមត្រីតូចមួយ ដោយក្រាលថង់ប្លាស្ទិក ។ កសិករអាចចិញ្ចឹមត្រីអណ្តែងឬទីឡាប់យ៉ា ដោយឱ្យចំណីពួកវាស៊ី ដូចជាកណ្តៀរ ឬកន្ទក់ជាដើម ។ម្យ៉ាងវិញទៀត កសិករអាចធ្វើជាទ្រុងមាន់មួយ ដោយទុកទីធ្លាខ្លះសម្រាប់ឱ្យមាន់រត់លេង ។ កសិករអាចចិញ្ចឹមសត្វតូចៗ ដូចជា កង្កែប ឬជន្លេន... ។ កសិករក៏អាចធ្វើកសិកម្មចម្រុះបានដែរ ដោយម្ខាងចិញ្ចឹមត្រី ហើយម្ខាងទៀតដាំបន្លែផ្សេងៗទៀត ។

លោកគាម មករាឌី គូសបញ្ជាក់ថា កសិករគួរតែយកចិត្តទុកដាក់លើការងារ ។ តួយ៉ាង គាត់ត្រូវគិតថា តើគាត់ត្រូវជ្រើសរើសដំណាំណា ដែលត្រូវនឹងដីរបស់គាត់? តើគាត់ត្រូវប្រើប្រាស់ជី ឬថ្នាំធម្មជាតិសម្លាប់សត្វល្អិតដូចម្តេច? ម្យ៉ាងទៀតកសិករត្រូវត្រួតពិនិត្យមើលថាដំណាំអ្វី? ឬចិញ្ចឹមសត្វអ្វី? ដែលមានទីផ្សារ និងអាចលក់ទៅបានតម្លៃថ្លៃនៅតំបន់របស់គាត់ជាដើម ។

លោកគាម មករាឌី បញ្ចេញយោបល់ថា ជាការល្អ! ដើម្បីកុំឱ្យមានការប្រថុយប្រថានខ្ពស់មុន នឹងសម្រេចចិត្តធ្វើអ្វី? កសិករគួរតែទៅរកសួរព័ត៌មាន ឬបទពិសោធន៍ពីអ្នកចិត្តខាងរបស់គាត់ដែលមានសួនដំណាំល្អឬចិញ្ចឹមសត្វបានជោគជ័យ ។គាត់អាចទៅពិគ្រោះយោបល់ជាមួយអ្នកបច្ចេកទេសកសិកម្មតាមអង្គការដូចជា អង្គការសេដាក ឬភ្នាក់ងារកសិកម្មរបស់រដ្ឋក៏បាន ។

លោកគាម មករាឌី សង្កត់ធ្ងន់ថា : "នោះគឺជាប្រការគួរឱ្យសោកស្តាយ ប្រសិនបើកសិករគាត់ទុកដីឱ្យនៅទំនេរ ។ តាមពិត ទោះបីជាវាមានទំហំតូច ប៉ុន្តែគាត់អាចធ្វើឱ្យវាមានប្រយោជន៍ក្នុងការដោះស្រាយម្ហូបអាហារសម្រាប់គ្រួសារ និងរកកម្រៃខ្លះបានដើម្បីចិញ្ចឹមជីវភាពទៀតផង" ។

## បរិស្ថាន

### សហគមន៍ជនជាតិភាគតិចព្រួយបារម្ភអំពីបម្រែបម្រួលគុណភាពទឹកតាមដងទន្លេស្រែពក

សហគមន៍ជនជាតិភាគតិចនៅភូមិភាគឦសាននៃប្រទេសកម្ពុជា កំពុងសម្តែងការព្រួយបារម្ភទាក់ទង និងបម្រែបម្រួលគុណភាពទឹក ព្រមទាំងចរន្តទឹកហូរនៅតាមដងទន្លេស្រែពក។

លោកភក ល្មឿ ប្រជាពលរដ្ឋ នៅឃុំជ័យឧត្តម ស្រុកលំផាត់ ខេត្តរតនគិរី ប្រាប់ឱ្យដឹងថា ទឹកទន្លេស្រែពកបច្ចុប្បន្ននេះ មិនដូចពីមុនទេ។ ជួនកាលទឹកមើលទៅធម្មតា ជួនកាលឡើងពណ៌ក្រហម និងជួនកាលទៀតល្អក់ និងគ្មានទឹកហូរនៅខែប្រាំង។ ជួនកាលភ្លៀងខ្លាំងជាប់ៗគ្នា ទឹកទន្លេគួរតែឡើងតែបែរជាអត់ទឹក។

លោកបញ្ជាក់ទៀតថា : "ឥឡូវនេះអ្នកស្រុកមួយចំនួនលែងចុះងូតទឹកផ្ទាល់ ដោយគេថារ៉ាវមាស់"។

តាមការអះអាងរបស់លោកភក ល្មឿ ការប្រែប្រួលគុណភាពទឹកនេះបណ្តាលមកពីការកសាងទំនប់វារីអគ្គិសនីនៅខាងលើប្រភពទឹក និងសកម្មភាពរុករក និងធ្វើអាជីវកម្មរ៉ែផ្សេងៗ ដែលបង្ហូរសារធាតុគីមីចូលមកក្នុងទន្លេ ទើបបណ្តាលឱ្យគុណភាពទឹកមានការប្រែប្រួល។ លោកបញ្ជាក់ថា : "ខ្ញុំឃើញតែបរទេសមានចិន ឬអឺរ៉ុបចុះមកតាមបណ្តោយទន្លេ ជាបន្តបន្ទាប់កាលពីខែប្រាំង។ ខ្លះមកបូមដី ខ្លះខួងដី ឬខួងថ្ម"។



Photo : B.Ponnarithy

លោកបានបញ្ជាក់ថា : "ខ្លះគេថា គេមកខួងរករ៉ែ។ ខ្លះគេថា មករកទីតាំងធ្វើទំនប់ស្រែពកបី។ ខ្ញុំមិនដឹងច្បាស់ទេ។ ប៉ុន្តែធ្វើម៉េច កុំឱ្យតែទឹកទន្លេប្រែប្រួល។ យើងពិបាករស់នៅណាស់"។ លោកបាននិយាយទៀតថា អ្នកស្រុកជនជាតិដើមភាគតិចពិបាករស់នៅណាស់បើគ្មានទន្លេ ឬគុណភាពទឹកទន្លេប្រែប្រួលនោះ។ លោកបានបញ្ជាក់ថា : "វប្បធម៌ និងជីវិតរស់នៅរបស់ប្រជាជន គឺសុទ្ធតែពឹងផ្អែកលើទន្លេនេះ"។

**ខាន់ ភីរម្យ**

# ក្រុមបព្វជិតាព្រះសហគមន៍កាតូលិក

## ក្រុមគ្រួសារបងស្រីអ្នកគង្វាលដ៏សប្បុរសផ្តល់ក្តីសង្ឃឹមដល់អ្នកទន់ខ្សោយ

**ជាត សំភី**

មណ្ឌលជលធារជីវិត ដែលស្ថិតនៅក្នុងខេត្តព្រះសីហនុស្ថិតនៅក្នុងតំបន់ឆ្នេរ និងជាខេត្តទេសចរណ៍នៃប្រទេសកម្ពុជា បានចាប់ផ្តើមដំណើរការ ដោយក្រុមបងស្រីគង្វាលដ៏សប្បុរសនៅពាក់កណ្តាលឆ្នាំ២០០៦។ បច្ចុប្បន្ននេះ ក្រុមបងស្រីមានបុគ្គលិកចំនួន ៦នាក់ ដែលបានធ្វើការជាមួយកុមារ និងស្ត្រីដែលបាត់បង់ឱកាស។ ជារៀងរាល់ថ្ងៃពួកគាត់បានបង្រៀនកូនសិស្សប្រហែល ៣០០នាក់ ជាពិសេសគឺស្ត្រី និងកុមារ និងមានកុមារាចូលរួមខ្លះៗដែរ។



បងស្រីខេរិន យិនយិន នៅក្រុមបងស្រីគង្វាលដ៏សប្បុរស មានប្រសាសន៍ថា: "យើងផ្តល់ឱកាសសិក្សាទៅដល់ស្ត្រី ដែលទទួលរងនូវភាពរើសអើង និងកុមារដែលខ្វះឱកាសឱ្យមាននូវសមត្ថភាព និងឱកាសដើម្បីចូលរួមក្នុងសង្គម។ យើងចង់បង្ហាញឱ្យពួកគេឃើញ និងឱ្យគេមានអារម្មណ៍ថា មនុស្សគ្រប់រូបសុទ្ធមានសិទ្ធិ និងភាពថ្លៃថ្នូរ"។ បងស្រីបន្តថា យើងក៏បង្រៀនស្ត្រីនៅក្នុងពន្ធនាគារផងដែរ។ យើងបង្រៀនក្មេងស្រី និងស្ត្រី អំពីមូលដ្ឋានគ្រឹះនៃភាសាអង់គ្លេសខ្មែរ ថៃ ធ្វើសក់ ម៉ាស្សាបាតជើងនិងធ្វើវត្ថុអនុស្សាវរីយ៍ផ្សេងៗ។ សម្រាប់កុមារាដែលខ្វះឱកាស យើងផ្តល់មូលដ្ឋានគ្រឹះសម្រាប់ភាសាអង់គ្លេស ភាសាខ្មែរ និងសុខភាពអនាម័យ។

បុគ្គលិករបស់មណ្ឌលក៏មានចុះទៅបង្រៀននៅក្លឹបកំសាន្តចំនួន ៨ ក្នុងក្រុងដែលមាននារីប្រមាណ ៥០នាក់។ ក្រុមគាត់ក៏មានបង្រៀនតាមភូមិចំនួន៥ និងធ្វើការជាមួយស្ត្រីនៅក្នុងពន្ធនាគារដែរ។

កាន់ដា ហេម៉ាណាត អ្នកគ្រូម្នាក់អាយុ ២៦ឆ្នាំ និយាយថាកូនសិស្សរបស់យើងមានជីវភាពក្រីក្រ។ អ្នកគ្រូបន្តថា: "ពួកគេគ្មានលុយ។ ដូច្នេះយើងជួយបង្រៀនពួកគេដោយសេចក្តីស្រឡាញ់ និងការយកចិត្តទុកដាក់"។ អ្នកគ្រូក៏បន្ថែមឱ្យដឹងដែរថា: "នៅពេលពួកគេមានបញ្ហាចំពោះការរស់នៅ យើងផ្តល់ការប្រឹក្សាយោបល់ដល់ពួកគេ ប្រសើរជាជាងការដែលយើងផ្តល់ប្រាក់ដល់ពួកគេ"។

អ្នកគ្រូកុយ ច័ន្ទស្រីរ័ត្ន អាយុ ២៥ឆ្នាំ បង្រៀនភាសាអង់គ្លេស មានប្រសាសន៍ថា ប្រវត្តិការសិក្សារបស់សិស្សគឺទាប។ អ្នកគ្រូក៏បន្តថា: "ដូច្នេះយើងពង្រឹងភាសាខ្មែរដល់ពួកគេសិន មុនពេលបង្រៀនភាសាអង់គ្លេស។ ប៉ុន្តែដំបូងអ្នកខ្លះមិនយល់ទេ"។ អ្នកគ្រូបន្ថែមថា សិស្សខ្លះមានដើមកំណើតជាជនជាតិវៀតណាម ជួនកាលពួកគេមានបញ្ហាក្នុងការទំនាក់ទំនង។ អ្នកគ្រូបញ្ជាក់ថា: "ខ្ញុំតែងអប់រំពួកគេឱ្យយល់ពីសារៈសំខាន់នៃសាមគ្គីភាព"។

អ្នកនាងពុទ្ធារី អាយុ២៥ឆ្នាំ បើកហាងអ៊ុតសក់មួយនៅសង្កាត់បីក្រុងព្រះសីហនុ និយាយថា អ្នកនាងអាចដំណើរការហាងនេះ ដោយសារក្រុមបងស្រីជួយ។ អ្នកនាងបានបន្តថា: "ខ្ញុំអាចរកបាន ១០ ដុល្លារ នៅខែភ្លៀង និង២០ដុល្លារ ក្នុងខែប្រាំង ជាមធ្យម ក្នុងមួយថ្ងៃ"។ អ្នកនាងក៏បន្ថែម: "ពីមុនខ្ញុំមិនចេះអក្សរ។ ឥឡូវខ្ញុំមានជំនាញ និងមានរបរជាមួយនិងចំណេះដឹងក្នុងការទំនាក់ទំនងក្នុងសង្គម។ ខ្ញុំមានអារម្មណ៍រីករាយណាស់"។

យុវនារី អ្នកទូទាត់ប្រាក់នៅក្នុងក្លឹបកំសាន្តមាត់សមុទ្រមួយរូប និយាយថា កញ្ញាអាចមានជីវភាពល្អប្រសើរជាងមុន ដោយសារក្រុមបងស្រី។ កញ្ញានិយាយថា: "គ្រួសាររបស់ខ្ញុំក្រីក្រ។ ប្រសិនបើពួកគាត់មិនមកបង្រៀនភាសាអង់គ្លេសនេះដោយមិនយកលុយទេ ខ្ញុំគ្មានមធ្យោបាយ និងរៀនភាសានេះ ដោយសារខ្ញុំចំណាយពេលវេលា ដើម្បីធ្វើការ និងប្រាក់ខែបន្តិចបន្តួចដើម្បីចិញ្ចឹមគ្រួសារ"។កញ្ញាបន្តថា: "ភាសាអង់គ្លេសបានជួយខ្ញុំឱ្យមានប្រាក់ខែ ៥០ ដុល្លារក្នុងមួយខែ ប្រសិនមិនអ៊ីចឹងទេ ខ្ញុំប្រហែលគ្រាន់ជាអ្នកលាងចាននៅក្នុងផ្ទះបាយ"។

យុវនារី អាយុ ២៩ឆ្នាំ មួយរូបទៀតជាអ្នកកាន់បញ្ជីនៅក្នុងក្លឹបកំសាន្តមួយនៅក្នុងក្រុង ក៏និយាយថា ក្រុមបងស្រីបានបង្រៀននូវភាសាអង់គ្លេសដល់កញ្ញា។ យុវនារីបន្តថា: "ខ្ញុំអាចរាក់ទាក់ជាមួយនិងភ្ញៀវ ជាពិសេសជនបរទេស។ ដូច្នេះការងាររបស់ខ្ញុំរីកចម្រើន។ ខ្ញុំអាចរកបាន ៧០ ដុល្លារ ក្នុងមួយខែ"។ យុវនារីបន្ថែមទៀតថា: "ក្រៅពីរៀនភាសាអង់គ្លេស ខ្ញុំអាចចេះចំណេះដឹងទូទៅអំពីការអប់រំសុខភាពការ ជួញដូរមនុស្ស សិទ្ធិមនុស្ស ទេសចរណ៍ផ្លូវភេទ ការការពារខ្លួនពីការឆ្លងជំងឺអេដស៍ និងការប្រែប្រួលអាកាសធាតុ..."។

ចំណែកបងស្រីខេរិន ប្រាប់ថា: "អ្វីដែលយើងបានធ្វើ គឺស្របទៅតាមដួងវិញ្ញាណរបស់ សន្តីម៉ារីយូ ហ្សេសសៀ ដែលជាអ្នកបង្កើតក្រុមគ្រួសារនេះឡើង។ យើងរីករាយណាស់ដែលយើងអាចមកធ្វើការនៅក្នុងប្រទេសកម្ពុជា"។

សមាគមន៍ក្រុមបងស្រីគង្វាលដ៏សប្បុរសចាប់ផ្តើមនៅឆ្នាំ១៨៣៥ ក្នុងប្រទេសបារាំងដោយសន្តីម៉ារី យូហ្វ្រេសសៀ ផេឡេតធៀ។ សហគមន៍នេះមានជំនឿលើ "ក្តីស្រឡាញ់មេត្តាករុណារបស់ព្រះជាម្ចាស់និងការផ្សះផ្សា"ជាមួយទស្សនៈថា"បុគ្គលម្នាក់មានតម្លៃជាងពិភពលោកទាំងមូល"។




Photos : Fountain of Life Center

សិស្សនារីខ្លះដែលធ្វើការនៅតាមក្លឹបកំសាន្តនានា ខិតខំរៀនសូត្រភាសាអង់គ្លេសដើម្បីធ្វើឱ្យជីវភាពប្រសើរជាងមុន




Photo : ICJ

ខាន់ ភីរម្យ

## តុលាការក្រុងឡាអេសម្រេចតាមការទាមទាររបស់រដ្ឋាភិបាលកម្ពុជា

តុលាការយុត្តិធម៌អន្តរជាតិក្រុងឡាអេប្រទេសហូឡង់ កាលពីថ្ងៃទី១៨ ខែកក្កដា បានសម្រេចសាលដីកាស្របតាមការទាមទាររបស់រដ្ឋាភិបាលកម្ពុជា ។

ឯកឧត្តមហោ ណាំហុង រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ បានមានប្រសាសន៍ថា ការសម្រេចរបស់តុលាការក្រុងឡាអេ គឺស្របតាមគោលដៅពីរ ដែលកម្ពុជាចង់បាន គឺដកទ័ពធ្វើឱ្យមានការឈប់បាញ់ជាអចិន្ត្រៃយ៍មួយនៅតំបន់ប្រាសាទព្រះវិហារ និងការទាមទារឱ្យមានអ្នកសង្កេតការណ៍ឥណ្ឌូនេស៊ីមកកាន់តំបន់ជម្លោះដែលថៃតែងបដិសេធ ។

នៅក្នុងសាលដីកាដែលបានធ្វើឡើងរយៈពេល ៤៥នាទី តុលាការនេះ បានសម្រេចជាឯកច្ឆ័ន្ទ ច្រានចោលនូវសំណើរបស់ថៃដែលបានស្នើសុំដកសំណើរបស់កម្ពុជា ។ ចង្អុលនូវវិធានការបណ្តោះអាសន្នមួយដោយតម្រូវឱ្យភាគីទាំងពីរដកជាបន្ទាន់នូវបុគ្គលិកយោធាដែលមានវត្តមានបច្ចុប្បន្នចេញពីតំបន់គ្មានយោធាមួយជាបណ្តោះអាសន្ន ។ ថៃមិនត្រូវរារាំងភាគីកម្ពុជា ចេញចូលដោយសេរីទៅកាន់ប្រាសាទព្រះវិហារ ឬការផ្គត់ផ្គង់ស្បៀងអាហារចំពោះបុគ្គលិក ដែលមិនមែនយោធានៅក្នុងប្រាសាទព្រះវិហារ ។ ឱ្យភាគីទាំងពីរបន្តកិច្ចសហប្រតិបត្តិការដែលបានព្រមព្រៀងក្នុងក្របខណ្ឌអាស៊ាន និងជាពិសេសអនុញ្ញាតឱ្យអ្នកសង្កេតការណ៍ដែលត្រូវបានតែងតាំងដោយអង្គការអាស៊ាន ឱ្យចូលទៅកាន់តំបន់គ្មានយោធាជាបណ្តោះអាសន្ន ។ តុលាការស្នើឱ្យភាគីទាំងពីរអត់ធ្មត់ មិនត្រូវធ្វើសកម្មភាពណាដែលនាំឱ្យជម្លោះដែលស្នើឱ្យតុលាការដោះស្រាយនោះ មានសភាពកាន់តែធ្ងន់ធ្ងរឬធំឡើង ។ ភាគីទាំងពីរត្រូវផ្តល់ព័ត៌មានដល់តុលាការទាក់ទងនឹងការអនុវត្តការប្រតិបត្តិរបស់ខ្លួនឆ្លើយតបទៅនឹងវិធានការជាបណ្តោះអាសន្នខាងលើរហូតដល់ពេលតុលាការចេញនូវសេចក្តីសម្រេចរបស់ខ្លួនឆ្លើយតបនឹងសំណើសុំបកស្រាយសាលក្រមឆ្នាំ១៩៦២ តុលាការនឹងនៅបន្តតាមដានកិច្ចការទាំងនេះ ដែលជាកម្មវត្ថុនៃសេចក្តីសម្រេចនេះ ។

## កុមារីម្នាក់ស្លាប់ដោយសារជំងឺគ្រុនផ្តាសាយបក្សី

កុមារីអាយុ ៤ឆ្នាំ មួយរូបនៅស្រុកមង្គលបុរី ខេត្តបន្ទាយមានជ័យ បានបាត់បង់ជីវិត ដោយសារជំងឺគ្រុនផ្តាសាយបក្សី ។ នេះបើតាមសេចក្តីប្រកាសព័ត៌មានរួមគ្នាដែលធ្វើឡើងដោយអង្គការសុខភាពពិភពលោក និងក្រសួងសុខាភិបាល ។

កុមារីម្នាក់នោះបានស្លាប់កាលពីថ្ងៃទី២០ កក្កដា កន្លងទៅនេះ ក្រោយពេលដែលនាងធ្លាក់ខ្លួនឈឺ១០ថ្ងៃ ។ នាងបានសម្រាកព្យាបាលនៅតាមគ្លីនិកមូលដ្ឋាន ហើយបានបញ្ជូនមកសង្គ្រោះនៅមន្ទីរពេទ្យជ័យវរ្ម័នទី៧ នៅសៀមរាបកាលពីថ្ងៃទី១៨កក្កដា ។ សំណាកឈាមរបស់នាងត្រូវបានគេបញ្ជូនមកពិនិត្យនៅវិទ្យាស្ថានប៉ាស្ទ័រ ដែលលទ្ធផលបង្ហាញថា នាងឆ្លងមេរោគអេចហ្វាយ អេនវ៉ាន់(H5N1) ។

កុមារីនេះ គឺជាជនរងគ្រោះទី ១៥ ដែលបានបាត់បង់ជីវិតដោយសារតែជំងឺ គ្រុនផ្តាសាយបក្សីចាប់តាំងពីវាបានឆ្លងចូលមកក្នុងប្រទេសកម្ពុជា ។

## អាមេរិកជំពាក់បំណុលគេរហូតដល់ទៅ ១៤៣០០០០០០លានដុល្លារ

អង្គការរូបិយវត្ថុអន្តរជាតិ បានធ្វើការព្រមានសហរដ្ឋអាមេរិកឱ្យរកវិធីដោះស្រាយវិបត្តិជំពាក់បំណុលរបស់ខ្លួន ដែលមានទឹកប្រាក់រហូតដល់ទៅ ១៤,៣លានលានដុល្លារ ដើម្បីចូលរួមសង្គ្រោះវិបត្តិសេដ្ឋកិច្ចសកល។ អង្គការនេះបានអះអាងថា នៅពេលដែលផ្សារហ៊ុនពិភពលោកបានទទួលផលប៉ះពាល់ខ្លាំងចំពោះការបរាជ័យចុងក្រោយបំផុតរបស់អាមេរិក ដែលមិនអាចសម្រេចបាននូវកិច្ចព្រមព្រៀងដើម្បីបង្កើនចំនួនប្រាក់បំណុលរបស់ខ្លួនដែលបានឡើងដល់ទៅដល់ចំនួននេះ។

លោកបារ៉ាក់ អូបាម៉ា ប្រធានាធិបតីអាមេរិក បានអះអាងថា អាមេរិកនឹងស្ថិតនៅក្នុងស្ថានភាពដ៏អាក្រក់ បើសិនអាមេរិកមិនអាចសម្រេចបាននូវកិច្ចព្រមព្រៀងស្តីអំពីការបង្កើនប្រាក់បំណុលទេនោះ។

នៅជុំវិញបញ្ហានេះ សភាអាមេរិកបានអនុម័តយល់ព្រមឱ្យមានវិធានការហើយ។ ហើយព្រឹទ្ធសភាពអាមេរិកក៏បានយល់ព្រម លើវិធានការនេះហើយដែរ ដែលធ្វើឱ្យប្រទេសមួយចំនួនមានការអបអរសាទរចំពោះដំណោះស្រាយរបស់អាមេរិកនៅលើបញ្ហានេះពីព្រោះអាចបញ្ចៀសពិភពលោកអំពីវិបត្តិជាបណ្តោះអាសន្ន។

## លោកស្រីយីងឡាក់ ស៊ីណាវ៉ាត្រា ជានាយករដ្ឋមន្ត្រីថៃថ្មី

លោកស្រីយីងឡាក់ ស៊ីណាវ៉ាត្រា ត្រូវបានព្រះមហាក្សត្រថៃតែងតាំងជានាយករដ្ឋមន្ត្រីកាលពីថ្ងៃទី ៨ ខែសីហា បន្ទាប់ពីគណបក្សភឿថៃបានឈ្នះឆ្នោតភ្លូកទឹកភ្លូកដី កាលពីថ្ងៃទី៣ ខែកក្កដា។ គណបក្សភឿថៃដែលជាគណបក្សស្និទ្ធនឹងអតីតនាយករដ្ឋមន្ត្រីថាក់ស៊ីន ស៊ីណាវ៉ាត្រាបានឈ្នះលើគណបក្សប្រជាធិបតេយ្យក្នុងប្រទេសថៃ ។

គណបក្សភឿថៃដែលដឹកនាំដោយ លោកស្រី យីងឡាក់ ស៊ីណាវ៉ាត្រា ដែលគេស្គាល់ថាជាប្អូនស្រីរបស់លោកថាក់ស៊ីនបានទទួលអាសនៈប្រមាណ ២៦៣កៅអី នៅខណៈដែលគណបក្សប្រជាធិបតេយ្យដែលដឹកនាំដោយលោកអាប់ប៊ីស៊ីត វ៉េចាជីវ៉ា បានទទួលត្រឹមតែ១៦២កៅអីនោះ ។ គណបក្សភូមិចៃថៃ ដែលស្ថិតនៅលំដាប់ទីបី មាន ៣៤កៅអី ។

លោកស្រីយីងឡាក់ស៊ីណាវ៉ាត្រា ត្រូវបានសភាថៃបោះឆ្នោតជ្រើសតាំងក្លាយជានាយករដ្ឋមន្ត្រីស្ត្រីដំបូងគេក្នុងប្រទេសថៃ កាលពីថ្ងៃទី ៥ ខែសីហា កន្លងទៅនេះ។ គណបក្សរបស់លោកស្រីយីងឡាក់ បានធ្វើរដ្ឋាភិបាលចម្រុះជាមួយនិងគណបក្សតូចៗមួយចំនួនទៀត ដែលទទួលបានអាសនៈក្នុងសភា ។



Photo : DR.

យោងតាម កាសែតបាងកកប៉ុស្តិ៍ លោកស្រីយីងឡាក់ត្រូវការកៅអីចំនួន ៣០០ ដើម្បីធ្វើឱ្យរដ្ឋាភិបាលរបស់លោកស្រីមានស្ថិរភាពក្នុងការគ្រប់គ្រងប្រទេស ។

# សិប្បករ : “ឧបសគ្គសម្រាប់សិប្បកម្មគឺដើមទុន ទីផ្សារ និងគុណភាព”

**ខាន់ ភីរម្យ**

*តើមនុស្សម្នាក់ៗអាចក្លាយជាសិប្បករបានដែរឬទេ ? ហើយបើចង់ក្លាយទៅជាសិប្បករ និងធ្វើសិប្បកម្មឱ្យបានជោគជ័យ តើម្នាក់ៗត្រូវគិតទៅដល់អ្វីជាមុន ? សម្រាប់ចម្លើយនេះ សូមប្រិយមិត្តជួបជាមួយលោកជួរ ឆេង ប្រធានក្រុមហ៊ុនគីស៊ុំឆេង ប្រូតេអ៊ីន ហ្វ៊ូដ ផលិតចំណីអាហារ តាមរយៈទំព័រអ្នកនាំសារ ដូចតទៅ :*

**អ្នកនាំសារ : តើលោកចាប់ផ្តើមបើកសិប្បកម្មរបស់លោកតាំងពីពេលណា ហើយផលិតអ្វីខ្លះ ?**

**លោកជួរ ឆេង** : សិប្បកម្មរបស់ខ្ញុំបានចាប់ផ្តើមបើកដំណើរការដំបូងជាមួយនិងផលិតផលតែមួយមុខទេ គឺសាច់ងៀតជាមួយ និងបរិមាណផលិតតិចតួចបំផុត ។ សិប្បកម្មនេះបានដំណើរការកាលពីឆ្នាំ ១៩៩៩ ជាមួយនិងដើមទុនត្រឹមតែ ១៥០០ដុល្លារតែប៉ុណ្ណោះ ហើយបន្តពង្រីកជាបន្តបន្ទាប់រហូតមកដល់សព្វថ្ងៃនេះ ។

**អ្នកនាំសារ : តាំងពីឆ្នាំ១៩៩៩ មកដល់ពេលនេះ តើសិប្បកម្មរបស់លោកកើនដើមទុនប៉ុន្មាន ? និងកំពុងតែផលិតចេញនូវផលិតផលអ្វីខ្លះ ?**



ផលិតផលមួយរបស់ក្រុមហ៊ុនគីស៊ុំឆេង ប្រូតេអ៊ីន ហ្វ៊ូដ

Photo : DR

**លោកជួរ ឆេង** : បើនិយាយអំពីដើមទុន ខ្ញុំនៅពុំទាន់បានបូកសរុបនៅឡើយទេ ដោយសារយើងបានបណ្តាក់ទុនទៅលើសិប្បកម្មនេះជាប់ជារហូត ។ ទុនរបស់យើងគឺវិនិយោគទៅលើសម្ភារៈ ដី និងវត្ថុធាតុដើម-ល- ។ បើនិយាយឱ្យចំទៅ យើងបានរីកចម្រើនបង្គួរដោយពីមុន យើងគ្មានកម្មករទេ គឺធ្វើតែនៅក្នុងក្រុមគ្រួសារតែប៉ុណ្ណោះ ។ ប៉ុន្តែឥឡូវនេះ យើងមានកម្មករ ៥នាក់ និងបានពង្រីកផលិតផលរបស់យើងបានលើស ៥មុខ មានដូចជា សាច់ងៀត ដំណាប់ល្ហុង ដំណាប់ស្វាយ នំណាណា ត្រសក់ និងឆៃប៉ូវគ្រឿងជាដើម ។

**អ្នកនាំសារ : ដំណាក់កាលដំបូងនៃផលិតកម្ម តើអ្វីដែលជាឧបសគ្គដំបូងសម្រាប់សិប្បករថ្មីថ្មោង ?**

**លោកជួរ ឆេង** : តាមបទពិសោធន៍របស់ខ្ញុំផ្ទាល់ ឧបសគ្គដំបូងដែលខ្ញុំបានជួបប្រទះគឺបញ្ហាទុនដើម្បីចាប់ផ្តើមផលិតកម្មរបស់យើង បន្ទាប់មកទៀត គឺបញ្ហាគុណភាពផលិតផលរបស់យើង ហើយបញ្ហាដែលធំចុងក្រោយនោះ គឺបញ្ហាខាងទីផ្សារតែម្តង ។ ដើម្បីទទួលបានជោគជ័យ យើងត្រូវតែពុះពារ និងច្នៃប្រឌិត នាដំណាក់កាលដំបូងនេះ គឺសំខាន់ណាស់ ហើយបើគេចាប់ទទួលស្គាល់ផលិតផលយើងនៅពេលណា សិប្បកម្មរបស់យើងដើរទៅមុខហើយ ។

**អ្នកនាំសារ : តើលោកមានអ្វីដែលជាសារផ្ញើទៅប្រជាពលរដ្ឋកម្ពុជាយើងទេ ?**

**លោកជួរ ឆេង** : ខ្ញុំមិនមានអ្វីជាវែងឆ្ងាយទេ ។ ប៉ុន្តែខ្ញុំសូមអំពាវនាវដល់ប្រជាពលរដ្ឋកម្ពុជាទាំងអស់សូមឱ្យជួយគាំទ្រផលិតផលដែលផលិតដោយជនជាតិខ្មែរ ។ បើបងប្អូនគាំទ្រផលិតផលខ្មែរ ក៏ដូចជាគាំទ្រដល់កសិករដែលកំពុងខិតខំបង្កបង្កើនផលដើម្បីឱ្យផលិតផលកសិកម្មរបស់ពួកគេមានទីផ្សារតាមរយៈការកែច្នៃផ្សេងៗ ដើម្បីបង្ការការជន់នៅលើទីផ្សារ ដែលនាំឱ្យតម្លៃផលិតផលរបស់ពួកគេធ្លាក់ចុះ ។ ការគាំទ្រដល់ផលិតផលខ្មែរក៏នឹងបង្កើតឱកាសសម្រាប់ការងារដល់យុវជន ឬក្មេងៗជំនាន់ក្រោយដែលកំពុងតែស្វះស្វែងរកការងារធ្វើ ។ ការគាំទ្រផលិតផលខ្មែរ ក៏ដូចជាគាំទ្រដល់ការអភិវឌ្ឍសេដ្ឋកិច្ចនៅក្នុងប្រទេសផងដែរ ។



Photo : V. Sambath

ផលិតផលសិប្បកម្មរបស់ខ្មែរភាគច្រើនត្រូវបានកែច្នៃចេញពីផលិតផលកសិកម្មដែលគុណភាពនៅមានកម្រិតនៅឡើយ។ ដូច្នេះ ប្រជាពលរដ្ឋតែងនិយមផលិតផលបរទេស។ ប៉ុន្តែការគាំទ្រទិញផលិតផលខ្មែរនឹងជួយឱ្យសេដ្ឋកិច្ចជាតិរីកចម្រើនកាន់តែខ្លាំងក្លា។

## សិប្បកម្មមួយស្រូបផលិតផលកសិកម្ម មួយឆ្នាំ ២០ តោន

លោកជួរ ឆេង ប្រធានក្រុមហ៊ុនគីស៊ុំឆេង ប្រូតេអ៊ីនហ្វ៊ូដ បានអះអាងថា សព្វថ្ងៃនេះ សិប្បកម្មរបស់លោក បានជួយស្រូបយកផលិផលកសិកម្មបានចំនួនប្រមាណជិត ២០តោនផងដែរ នៅក្នុងមួយឆ្នាំៗ។

លោកបន្តឱ្យដឹងទៀតដែរថា សិប្បកម្មរបស់លោកមួយត្រូវការវត្ថុធាតុដើមទំហំប៉ុណ្ណឹង ចុះទម្រាំនៅទូទាំងប្រទេស ដែលមានសិប្បកម្មជាច្រើនដែលកំពុងតែផលិតផលិតផលផ្សេងៗចេញពីផលិតផលកសិកម្ម តើវាត្រូវការប៉ុណ្ណា ? ដូច្នេះ បើប្រជាពលរដ្ឋគាំទ្រផលិតផល សិប្បកម្មទាំងនោះនឹងកាន់តែស្រូបយកផលិតផលកសិកម្មកាន់តែច្រើនថែមទៀតជាមិនខាន។

## បទយកការណ៍

# ៥០០លានដុល្លារ កម្ចីពីធនាគារអេឌីប៊ីសម្រាប់អភិវ

**ខាន់ ភីរម្យ**

ធនាគារអភិវឌ្ឍន៍អាស៊ី កាលពីដើមខែកក្កដាកន្លងទៅនេះ បានប្រកាសផ្តល់ប្រាក់កម្ចីសម្បទានក្នុងទំហំទឹកប្រាក់រហូតដល់ ៥០០លានដុល្លារ ដើម្បីគាំទ្រសកម្មភាពរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការជំរុញកំណើនសេដ្ឋកិច្ច និងកាត់បន្ថយនូវភាពក្រីក្រក្នុងរយៈពេលបីឆ្នាំខាងមុខ។

ការផ្តល់នេះធ្វើឡើង តាមរយៈកម្មវិធីភាពជាដៃគូរវាងរាជរដ្ឋាភិបាលកម្ពុជា និងធនាគារអភិវ-ឌ្ឍន៍អាស៊ីសម្រាប់ឆ្នាំ២០១១-២០១៣។ ឆ្លងតាមកម្មវិធីនេះ ធនាគារអភិវឌ្ឍន៍អាស៊ីបានប្រកាសអំពីផែនការវិនិយោគធនធានថ្មីរបស់ខ្លួន ក្នុងចំនួនទឹកប្រាក់ដ៏លើសលុបនេះ គឺដើម្បីគាំទ្រដល់សកម្មភាពអភិវឌ្ឍន៍លើវិស័យធំៗ មួយចំនួនដូចជា អភិវឌ្ឍន៍វិស័យកសិកម្ម ធារាសាស្ត្រជនបទ ហេដ្ឋារចនាសម្ព័ន្ធអប់រំ និងវិស័យហិរញ្ញវត្ថុជាដើម។

លោកភីធ័រ ប្រ៊ីមបល អ្នកសេដ្ឋកិច្ចវិទូជាន់ខ្ពស់នៃធនាគារអភិវឌ្ឍន៍អាស៊ី ប្រចាំនៅប្រទេសកម្ពុជា អះអាងថា យុទ្ធសាស្ត្រភាពជាដៃគូនៅកម្ពុជានេះជាផែនទីបង្ហាញផ្លូវនៃការអភិវឌ្ឍមួយ ដែលសំដៅគាំទ្រយន្តការសេដ្ឋកិច្ច និងសង្គមដើម្បីកាត់បន្ថយភាពក្រីក្រនៅតំបន់ជនបទ។ លោកប្រាប់ឱ្យដឹងថា យុទ្ធសាស្ត្រភាពជាដៃគូ នៅប្រទេសនេះដាក់ចេញនូវផែនទីបង្ហាញផ្លូវ ដ៏មានមហិច្ឆតាមួយដើម្បីផ្តល់ប្រយោជន៍ឱ្យដល់ប្រជាជនក្រីក្រនៃប្រទេសកម្ពុជាតាមរយៈការអភិវឌ្ឍន៍ជនបទតាមបែបរួមផ្សំ។

ដោយសារមានប្រជាពលរដ្ឋជិត៧៥% កំពុងតែប្រកបរបរកសិកម្ម ការផ្តោតការយកចិត្តទុកដាក់លើភាពប្រកួតប្រជែងរបស់កសិដ្ឋាន សហគ្រាសកសិពាណិជ្ជកម្ម និងហេដ្ឋារចនាសម្ព័ន្ធជនបទ នឹងបង្កើនការងារ និងចំណូល ក៏ដូចជាការលើកកម្ពស់សន្តិសុខស្បៀងផងដែរ។ ធនាគារអភិវឌ្ឍន៍អាស៊ីនឹងបន្តកែលំអ លើប្រព័ន្ធធារាសាស្ត្រ ដើម្បីបង្កើនផលិតភាពកសិកម្ម ដែលនេះជាការគាំទ្រលើគោលនយោបាយផលិតកម្មស្រូវ និងជម្រុញការនាំចេញអង្ករបស់រដ្ឋាភិបាល។

ការពង្រឹងទំនាក់ទំនងរវាងតំបន់ទីក្រុង និងជនបទ និងការភ្ជាប់ទំនាក់ទំនងក្នុងប្រទេសជាមួយនិងប្រទេសជិតខាង នឹងពង្រីកនូវឱកាសធុរកិច្ចបន្ថែមទៀត។ ការវិនិយោគលើវិស័យហិរញ្ញវត្ថុកិច្ច ការសម្រួលពាណិជ្ជកម្ម និងការបណ្តុះបណ្តាលបច្ចេក-ទេស និងវិជ្ជាជីវៈនឹងធ្វើឱ្យបរិយាកាសធុរកិច្ចកាន់តែមានភាពប្រសើរជាងមុន។ ការអភិវឌ្ឍធនធានមនុស្ស ក៏នឹងត្រូវធ្វើឡើងតាមរយៈវិធានការនានាសំដៅសម្រេចនូវសមធមិយេនឌ័រ ការពង្រីកសេវាផ្គត់ផ្គង់ទឹកនិងអនាម័យតំបន់ជនបទនិងការបង្កើនលទ្ធភាពទទួលបានការអប់រំកម្រិតមធ្យមសិក្សឱ្យប្រកបដោយគុណភាព។ ធនាគារអភិវឌ្ឍន៍អាស៊ីក៏នឹងបញ្ជ្រាបនូវរាល់សកម្មភាព ដែលធ្វើឱ្យធន់នឹងការប្រែប្រួលអាកាសធាតុ ទៅក្នុងគម្រោង ដែលកំពុង អនុវត្តក៏ដូចជាគម្រោងថ្មីៗដោយប្រើប្រាស់ថវិការបស់កម្មវិធីសាកល្បងជាសកល។

យុទ្ធសាស្ត្រភាពជាដៃគូនៅប្រទេសនេះ ទទួលបានការគាំទ្រតាមរយៈការផ្តោតជាសំខាន់លើការគ្រប់គ្រងវិស័យសាធារណៈ គឺដូចជា ការគ្រប់គ្រង



### ប្រាក់កម្ចីពីធនាគារអភិវឌ្ឍន៍អាស៊ី គឺជាប្រាក់កម្ចីសម្បទាន

លោកគីម ចន្ថា មន្ត្រីកម្មវិធីនៃធនាគារអភិវឌ្ឍន៍អាស៊ី ប្រាប់ឱ្យដឹងថា ប្រាក់កម្ចីដែលធនាគារអភិវឌ្ឍន៍អាស៊ីផ្តល់ឱ្យ គឺជាកម្ចីសម្បទានដែលអនុគ្រោះដល់ប្រទេសកម្ពុជាចំនួន ៨ឆ្នាំ ឱ្យសងក្នុងអត្រាការប្រាក់ ១% ក្នុងមួយឆ្នាំ បន្ទាប់មកប្រទេសកម្ពុជាត្រូវដំណើរការសងចាប់ពី២០ ទៅ៣០ឆ្នាំ នៅក្នុងអត្រាការប្រាក់ ១,៥% ក្នុងមួយឆ្នាំ។

យោងទៅតាមគេហទំព័ររបស់ធនាគារអភិវឌ្ឍន៍អាស៊ីបានឱ្យដឹងថា មកដល់ពេលនេះ កម្ពុជាបានទទួលប្រាក់កម្ចីពីធនាគារនេះ ចំនួន ១,១៧ពាន់លានដុល្លារ ក្នុងនោះគម្រោង ៥៦គម្រោងជាជំនួយឥតសំណងពីមូលនិធិអភិវឌ្ឍន៍អាស៊ី តម្លៃ ២៥៥,៧១លានដុល្លារ និងជំនួយបច្ចេកទេសមានតម្លៃប្រមាណជា ១១២,៨៦លានដុល្លារ។ កម្ពុជាបានក្លាយជាសមាជិករបស់ស្ថាប័ននេះតាំងតែពីឆ្នាំ១៩៦៦មក។

# អភិវឌ្ឍន៍ពីឆ្នាំ២០១១_២០១៣



Photo : Meng Kimlong

ហិរញ្ញវត្ថុសាធារណៈវិមជ្ឈការ និងវិសហមជ្ឈការ និងការអភិវឌ្ឍសមត្ថភាពនៃវិស័យសាធារណៈ ។ ដោយទទួលស្គាល់ថាអភិបាលកិច្ចល្អ (ការប្រឆាំងអំពើពុករលួយ ការគ្រប់គ្រងហិរញ្ញវត្ថុ សាធារណៈ និងលទ្ធកម្ម) គឺជាបញ្ហាសំខាន់មួយនៅក្នុងប្រទេសកម្ពុជា ផែនការវាយតម្លៃហានិភ័យ និងគ្រប់គ្រងហានិភ័យអភិបាលកិច្ចប្រចាំប្រទេសនេះ ដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយមួយ ក៏ត្រូវបានរៀបចំឱ្យដំណើរឡើងផងដែរ ។

លោកភីធ័រមានប្រសាសន៍ឱ្យដឹងដែរថា: "យុទ្ធសាស្ត្រថ្មីៗ នឹងជួយប្រទេសកម្ពុជា ក្នុងការអភិវឌ្ឍវិស័យឯកជន ប្រកបដោយភាពរស់រវើក មានភាពចម្រុះវិស័យសេដ្ឋកិច្ច និងការធ្វើសមាហរណកម្មប្រទេសកម្ពុជាចូលទៅក្នុងទីផ្សារតំបន់ ។ យើងនឹងធ្វើការងារ ដើម្បីទាក់ទាញហិរញ្ញប្បទាន ពីវិស័យឯកជនបន្ថែមទៀត សម្រាប់គម្រោងសំខាន់ៗតាមរយៈភាពជាដៃគូរវាងវិស័យសាធារណៈ និងវិស័យឯកជន" ។ លើសពីនេះធនាគារអភិវឌ្ឍន៍អាស៊ី នឹងធ្វើឱ្យប្រសើរនូវកិច្ចសម្រួលការដឹកជញ្ជូន និងពាណិជ្ជកម្មនៅតាមច្រករបៀងសេដ្ឋកិច្ចនៅភាគខាងត្បូង ដែលភ្ជាប់ទំនាក់ទំនងទីក្រុងបាងកក ជាមួយនិងទីក្រុងហូជីមិញតាមរយៈ រាជធានីភ្នំពេញ ក្នុងគោលបំណងលើកកម្ពស់ទំនាក់ទំនងទីផ្សារភាពប្រកួតប្រជែងពាណិជ្ជកម្ម និងទេសចរណ៍ នៅក្នុងក្របខណ្ឌមហាអនុតំបន់ទន្លេមេគង្គ ។

លោកគីម ចន្ថា មន្ត្រីកម្មវិធី របស់ធនាគារអភិវឌ្ឍន៍អាស៊ីប្រាប់ឱ្យដឹងថា នេះគឺជាយុទ្ធសាស្ត្រមួយដែលទទួលបានបន្ទាប់ពីការពិគ្រោះយោបល់ជាមួយនឹងមន្ត្រីសង្គមស៊ីវិលមួយចំនួន ។ នេះមិនមែនជាគម្រោងដែលអនុម័តដោយបរទេសទាំងស្រុង ដូចជាគម្រោងវិនិយោគមុនៗ របស់ធនាគារអភិវឌ្ឍន៍អាស៊ីនោះទេ ។ លោកបញ្ជាក់ថា: "នេះគឺជាគម្រោងវិនិយោគទីមួយដែលមានជនជាតិខ្មែរបានចូលរួមពិភាក្សា និងពិគ្រោះយោបល់មុនពេលដែលធនាគារអភិវឌ្ឍន៍អាស៊ីសម្រេចកាលពីដើមខែកក្កដានេះ" ។

តាមការអះអាងរបស់លោកគីម ចន្ថា ទឹកប្រាក់ដែលអនុម័តដោយធនាគារអភិវឌ្ឍន៍អាស៊ីនឹងជួយដល់ប្រទេសកម្ពុជា រយៈពេល ៣ឆ្នាំ នៅលើវិស័យកសិកម្ម ប្រព័ន្ធធារាសាស្ត្រ ការកសាងទីប្រជុំជន និងហេដ្ឋារចនាសម្ព័ន្ធផ្សេងៗដែលជាយន្តការគាំទ្រដល់កសិកម្ម និងការអភិវឌ្ឍជនបទនេះ មានតម្លៃសរុបប្រមាណ ២៧០លានដុល្លារ ។ លោកគីម ចន្ថា បន្តទៀតថា ការងារវិមជ្ឈការ និងការកសាងអគ្គិសនីជនបទមានទឹកប្រាក់ទំហំប្រមាណ ១០០លានដុល្លារ ។ វិស័យអប់រំមានទឹកប្រាក់ប្រមាណជា ៦០ លានដុល្លារ ។ ចំណែកវិស័យហិរញ្ញវត្ថុ គឺមានតម្លៃប្រមាណជា ៤៥លានដុល្លារ-ល-។

ជុំវិញបញ្ហានេះមន្ត្រីរាជការមួយរូបដែលសុំមិនបញ្ចេញអត្តសញ្ញាណ បានបង្ហាញអំពីគំនិតសុទិដ្ឋិនិយមខ្លះ និងទុទិដ្ឋិនិយមខ្លះ ។

លោកបានឱ្យដឹងថា យើងសប្បាយដោយសារតែបរទេសគាំទ្រ និងឱ្យយកលុយមកចាយ ។ ប៉ុន្តែនេះពុំមែនជាការដែលគេឱ្យយើងមកចាយលេងៗទេគឺជាការដែលគេឱ្យយើងជាប្រាក់កម្ចី ដែលមានន័យថា យើងទាំងអស់គ្នាត្រូវសងទៅគេវិញនៅថ្ងៃណាមួយដែលនេះជារឿងដែលយើងព្រួយបារម្ភ ។

លោកនូវ សីហា អ្នកស្រាវជ្រាវជាន់ខ្ពស់ប្រចាំនៅវិទ្យាស្ថានសេដ្ឋកិច្ចកម្ពុជា អះអាងថា បំណុលគឺជារឿងមួយ ។ តែតម្រូវការទុនសម្រាប់យកមកអភិវឌ្ឍសេដ្ឋកិច្ចជារឿងដែលចាំបាច់ផងដែរ ។ ក្នុងកាលៈទេសៈបច្ចុប្បន្ននេះ កម្ពុជាកំពុងត្រូវការទុនជាច្រើនលើសលុប ដើម្បីយកមកកសាងយន្តការសេដ្ឋកិច្ចរបស់ខ្លួន ដើម្បីជំរុញការអភិវឌ្ឍប្រទេសខណៈដែលប្រាក់ចំណូលជាតិនៅមិនទាន់មានលទ្ធភាពទប់ទល់បាននោះ ។ លោកបញ្ជាក់ថា: "សព្វថ្ងៃនេះប្រាក់ចំណូលពីពន្ធ អាចទប់ទល់តែជាមួយនិងប្រាក់ខែមន្ត្រីរាជការប៉ុណ្ណោះ ។ ដូច្នេះយើងត្រូវការទុនបន្ថែមទៀតដើម្បីវិនិយោគបង្កើនប្រាក់ចំណូលរបស់យើង ។ជាមួយកំណើននៃសេដ្ឋកិច្ចដែលយើងទទួលបានពី៦ ទៅ ៧% ក្នុងមួយឆ្នាំ ខ្ញុំគិតថា យើងនឹងមិនមានបញ្ហាក្នុងការសងបំណុលគេនោះទេ" ។ លោកនិយាយថា ប្រទេសនានានៅលើពិភពលោកសុទ្ធតែមានជំពាក់បំណុលបរទេសទាំងអស់ ហើយពិសេសគឺជំពាក់ស្ថាប័នហិរញ្ញវត្ថុធំៗដូចជាធនាគារអភិវឌ្ឍន៍អាស៊ី និងធនាគារពិភពលោកជាដើម ។

### កម្ពុជានាំចេញអង្ករកើនឡើង

លោកនូវ សីហា អ្នកស្រាវជ្រាវជាន់ខ្ពស់នៃវិទ្យាស្ថានសេដ្ឋកិច្ចកម្ពុជាអះអាងថា ជាមួយនិងយន្តការអភិវឌ្ឍន៍សេដ្ឋកិច្ចផ្សេងៗ ដូចជាហេដ្ឋារចនាសម្ព័ន្ធ ប្រព័ន្ធធារាសាស្ត្រជាដើមនោះ ផែនការនាំចេញអង្កររបស់កម្ពុជាទៅកាន់ទីផ្សារអន្តរជាតិឱ្យបាន ១លានតោន នៅមុនឆ្នាំ២០១៥ នេះអាចនឹងទទួលបានជោគជ័យ។ លោកបានឱ្យដឹងថា ការអភិវឌ្ឍន៍ និងជំរុញវិនិយោគលើប្រព័ន្ធធារាសាស្ត្រ និងហេដ្ឋារចនាសម្ព័ន្ធជនបទនេះគឺសំខាន់ណាស់សម្រាប់ជំរុញផលិតកម្ម និងពាណិជ្ជកម្មអង្ករនៅក្នុងប្រទេស។

តួលេខចុងក្រោយរបស់ក្រសួងពាណិជ្ជកម្មបង្ហាញថា ការនាំចេញអង្កររបស់កម្ពុជាបានទទួលកំណើនរហូតដល់ ៣៦៩% ក្នុងរយៈពេល ៦ខែដើមឆ្នាំនេះ។ ប្រភពដដែលនេះបានឱ្យដឹងថា ពីខែមករា ដល់ខែមិថុនាឆ្នាំ២០១១នេះ កម្ពុជាបាននាំចេញអង្ករប្រមាណជា ៨០៤៤២តោន ទៅកាន់ទីផ្សារនៅអឺរ៉ុប និងប្រទេសផ្សេងៗ ខណៈដែល ៦ខែ ដើមឆ្នាំមុន កម្ពុជាអាចនាំចេញបានតែត្រឹម ១៧១៤៤តោន ប៉ុណ្ណោះ។

## រតនគិរីជាព្រះសហគមន៍តូចមួយនៅភូមិភាគព្រៃសាន្ត ប្រទេសកម្ពុជា



Photo : B.Ponnarithy

អគារមួយខ្នងស្ថិតនៅលើដីឡូមួយកន្លែង ហួសពីរង្វង់មូលផ្សារបានលុង ប្រមាណជា ២០០ម៉ែត្រ ឆ្ពោះទៅកាន់រមណីយដ្ឋានបឹងយក្សឡោម និងនៅឆ្វេងដៃជាប់នឹងធនាគារឯកជនមួយ គឺជាព្រះវិហារនៃព្រះសហគមន៍កាតូលិកខេត្តរតនគិរីនៃភូមិភាគកំពង់ចាម ។ សមាជិកប្រមាណពី៥០ទៅ១០០នាក់នៃព្រះសហគមន៍នេះ តែងតែជួបជុំគ្នាធ្វើពិធីអភិបូជា នៅរៀងរាល់ចុងសប្ដាហ៍ ។

លោកលី គីមយន់ គណៈកម្មការព្រះសហគមន៍រតនៈគិរី មានប្រសាសន៍ថា ព្រះសហគមន៍រតនគិរីជាព្រះសហគមន៍តូចមួយក្នុងភូមិភាគកំពង់ចាម ។ លោក មានប្រសាសន៍ទៀតថា ព្រះសហគមន៍មិនសូវមានសកម្មភាពអ្វីធំដុំទេ ក្រៅពីជួបជុំគ្នាធ្វើពិធីអភិបូជានៅរៀងរាល់ចុងសប្ដាហ៍ ។ ក្រៅពីអភិបូជាយើងមានសកម្មភាពតិចតួចទាក់ទងនឹងការបណ្ដុះបណ្ដាលភាសាអង់គ្លេស កូរ៉េ និងខ្មែរ ។

លោកលី គីមយន់ បញ្ជាក់ថា : "យើងខិតខំឱ្យមានដូចជាការបង្រៀននូវភាសារអង់គ្លេស និងខ្មែរ ដែលមានគ្រូស្ម័គ្រចិត្តជនជាតិខ្មែរ ។ សម្រាប់ភាសាកូរ៉េវិញ គឺដំណើរការដោយអ្នកគ្រូស្ម័គ្រចិត្តកូរ៉េ" ។

បើតាមប្រសាសន៍របស់លោកលី គីមយន់ នៅទូទាំងខេត្តរតនគិរីនេះ ជាពិសេសនៅទីក្រុងបានលុងនេះ គឺមានព្រះវិហារគ្រីស្ដសាសនាសរុប ទាំងអស់ ៤កន្លែង ។ តែព្រះវិហារកាតូលិកមានតែមួយកន្លែងទេ ក្រៅពីនោះ គឺព្រះវិហារប្រូតេស្ដង់ ។

លោកបានបញ្ជាក់ថា: "ព្រះសហគមន៍រតនគិរីមិនទាន់មានគ្រូអប់រំជំនឿទេ ដោយសារសមាជិកព្រះសហគមន៍ភាគច្រើនរវល់ទៅនឹងកិច្ចការរកស៊ីដែលធ្វើឱ្យភ្លេចគិតពីបញ្ហានេះ ។រីឯព្រះវិហារដែលមើលឃើញល្អស្អាតនេះគឺទើបតែសាងសង់រួចកាលពីឆ្នាំ២០០៩កន្លងទៅ ។ ពីមុន សមាជិកព្រះសហគមន៍ តែងតែជួបជុំគ្នានៅក្នុងព្រះវិហារមួយ ដែលធ្វើពីឈើយ៉ាងចំណាស់ ដែលជាអតីតការិយាល័យរបស់អង្គការខូអ័រ ។"

**ភីរម្យ**

## យុវជនព្រះសហគមន៍ច្រាបវាលដាំកូនឈើដើម្បីជួយដល់បរិស្ថាន



Photo : An Rithyrath

យុវជននៅព្រះសហគមន៍ច្រាបវាល ១១នាក់ នាំគ្នាដាំដើមឈើនៅតាមរបងព្រះសហគមន៍កាលពីថ្ងៃទី៣១ កក្កដា ឆ្នាំ២០១១កន្លងទៅ ។

កូនឈើ ២០ដើម បានទទួលពីក្រុមបរិស្ថាននៃព្រះសហគមន៍បាត់ដំបង ដែលធ្វើជាអ្នកណែនាំក្នុងកម្មវិធីដាំកូនឈើទាំងនេះដែរ ។

កម្មវិធីនេះរៀបចំឡើងដោយលោកអាយ ធី ដែលជាប្រធាននៅក្នុងផ្នែកជួយថែរក្សាព្រៃឈើ ។ លោកអាយ ធី បាននិយាយថា ការដាំកូនឈើទាំងអស់នេះ មានគោលបំណងចង់ឱ្យយុវជន ក៏ដូចជាមនុស្សនៅលើពិភពលោកចូលរួមដាំកូនឈើឱ្យបានច្រើនដើម្បីជួយបរិស្ថាន ឱ្យល្អប្រសើរឡើងវិញ ។ យើងបានឃើញថា នៅពេលបច្ចុប្បន្ននេះ អាកាសធាតុមានការប្រែប្រួលយ៉ាងខ្លាំងព្រោះថា ព្រៃឈើបានបាត់បង់ជាច្រើន ។ដើម្បីចូលរួមចំណែកក្នុងការថែរក្សាព្រៃឈើអ្នកដែលកាប់ឈើមួយដើមត្រូវដាំមួយដើមឡើងវិញមួយដើម ។

លោកអាយ ធី បានមានប្រសាសន៍បន្តថា : "ខ្ញុំស្រឡាញ់បរិស្ថានណាស់ ជាពិសេសខ្ញុំចង់ឱ្យមនុស្សទាំងអស់ចូលចិត្ត និងចាប់អារម្មណ៍ទៅលើបរិស្ថាននៅជុំវិញខ្លួន ដោយថែរក្សាដើមឈើ" ។

យុវជននៅព្រះសហគមន៍កាតូលិកច្រាបវាលទាំងអស់ មានការសប្បាយរីករាយក្នុងការនាំគ្នាដាំកូនឈើទាំងនោះដោយមានទឹកមុខញញឹម និងរួមសាមគ្គីគ្នាទៅវិញទៅមក ។

**អាន ឫទ្ធីរដ្ឋ**

### សប្បុរសជនបែលហ្សិកជួយសង់ផ្ទះឱ្យព្រះសហគមន៍នៅកំពត

ការចាប់ផ្ដើមសាងសង់ផ្ទះដែលជាអំណោយរបស់សប្បុសជនមកពីប្រទេសប៊ែលហ្ស៊ិកជូនប្រជាជនក្រីក្រនៅព្រះសហគមន៍កាតូលិកព្រៃប្រស់ពីរខ្នង និងជុំគិរីមួយខ្នង បានធ្វើឡើងកាលពីថ្ងៃ១១ កក្កដាកន្លងទៅនេះ។ ព្រះសហគមន៍ទាំងពីរនេះ ស្ថិតនៅតំបន់កំពតនៃព្រះសហគមន៍ភូមិភាគភ្នំពេញ។

លោកបូជាចារ្យវ៉ូណេ ប៉ប ដែលបានដឹកនាំក្រុមយុវសិស្សមកពីប្រទេសបែលហ្ស៊ិក បានមានប្រសាសន៍ថា ទង្វើ និងសកម្មភាពទាំងនេះ គឺជាការយកចិត្តទុកដាក់របស់ក្រុម ដោយសារពួកគេមានសេចក្ដីស្រឡាញ់ ដែលតែងមានចំពោះប្រជាជន និងនេះក៏ជាកិច្ចការដែលព្រះជាម្ចាស់ទ្រង់ចាត់ឱ្យមក។

លោកបូជាចារ្យវ៉ូណេ ប៉បបន្តឱ្យដឹងទៀតថា ការជឿរបស់បុគ្គលម្នាក់ៗ គឺមានលក្ខណៈខុសគ្នាទៅតាមកាយវិការដែលខុសគ្នា ប៉ុន្តែទោះជាយ៉ាងណាសកម្មភាពដែលធ្វើឡើង គឺក្នុងគោលបំណងតែមួយពោលគឺការយកចិត្តទុកដាក់ចំពោះគ្នាទៅវិញទៅមកក្នុងនាមជាបុត្រធីតារបស់ព្រះអង្គម្ចាស់។

អំណោយចិត្តដ៏សប្បុរសរបស់ក្រុមនិស្សិតជនជាតិប៊ែលហ្ស៊ិក ដែលដឹកនាំដោយលោកបូជាចារ្យវ៉ូណេ ប៉ប បានធ្វើឡើងជាលើក ទី៤ហើយនៅតំបន់នោះ។

**សុខន**

## យុទ្ធសាស្ត្របំពេញតម្រូវការរបស់ខ្លួនដោយអហិង្សា

"យុវជនភាគច្រើនគឺចូលចិត្តប្រើហិង្សាចំពោះក្រុមគ្រួសារខ្លួន និងមិត្តភក្តិនៅពេល ដែលពួកគេចង់ធ្វើកិច្ចការអ្វីមួយ ហើយមានការហាមឃាត់ពីអ្នកទាំងនោះ"។ នេះបើតាមប្រសាសន៍របស់លោក ផាន បូរ៉ា ដែលធ្វើការពាក់ព័ន្ធនឹងយុវជន ក៏ដូចជាការធ្វើអង្កេតរបស់លោកផ្ទាល់អំពីស្ថានភាពរបស់យុវជនដែលរស់នៅក្នុងភូមិ-ស្រុករបស់លោក។

លោកបានមានប្រសាសន៍ដូច្នេះ ក្នុងអង្គសិក្ខាសាលាមួយដែលរៀបចំធ្វើឡើងកាលពីថ្ងៃទី៤-៨ ខែកក្កដា កន្លងទៅនៅព្រះវិហារកំពង់ចាម ក្នុងឃុំវាល់វង់ ក្រុងកំពង់ចាម។ សិក្ខាសាលានេះមានការអញ្ជើញចូលរួមជាវាគ្មិនមកពីអង្គការ អ៊ិនណឺ ឆេង (Inner Change) ដែលធ្វើការងារពាក់ព័ន្ធនឹងបញ្ហារបស់យុវជនផ្ទាល់ និងព្រមទាំងសិស្ស-និស្សិត និងបុគ្គលិកអង្គការចូលរួមសរុប ៣៦នាក់។

លោកផាន បូរ៉ា បាននិយាយថា មូលហេតុចម្បងនៃការនាំឱ្យមានអំពើហិង្សាផ្លូវកាយ និងពាក្យសម្តីគឺបណ្តាលមកពីការប្រើប្រាស់គ្រឿង និងការអូសទាញនៃសម្ភារៈនិយម។ ដូច្នេះក្រុមរបស់លោកក៏រៀបចំឱ្យមាននូវសិក្ខាសាលា ដែលនិយាយផ្តោតសំខាន់ទៅនឹងយុទ្ធសាស្ត្រដើម្បីបំពេញតម្រូវការរបស់ខ្លួនដោយអហិង្សា។

លោកអេង វុត្ថា សិក្ខាកាម និងក៏ជាសិស្សរៀនថ្នាក់ទី១២ បាននិយាយថា ទោះបីនេះជាលើកទី១របស់លោកដែលបានចូលរួមសិក្ខាសាលា តែលោកអាចឆ្លុះបញ្ចាំងទង្វើរបស់លោកនាពេលកន្លងមក។ លោកជាអ្នកមិនចេះទទួលយកយោបល់អ្នកដទៃ ហើយមានចិត្តមានះចង់ឈ្នះទាំងដឹងថា ខ្លួនធ្វើខុសក៏ដោយ។ លោកបញ្ជាក់ថា: "អ្វីដែលខ្ញុំរំពឹងពីសិក្ខាសាលានេះ គឺការស្គាល់ខ្លួនឯង"។

កញ្ញាឃុន សុខុម ជាយុវសិស្សម្នាក់បាននិយាយដែរថា កញ្ញាមានអារម្មណ៍ឆេវឆាវ និងចូលចិត្តប្រើសម្តីធំៗដាក់ឪពុកម្តាយ កាលពីពេលមុន។ ប៉ុន្តែវគ្គសិក្សានេះ គឺបានជំរុញឱ្យកញ្ញាយល់អំពីសេចក្តីត្រូវការរបស់ខ្លួន និងការទប់កំហឹងដោយមិនបង្កហេតុដល់អ្នកដែលនៅជុំវិញខ្លួន។

**អ៊ឹម សុខន**

## ក្មេងៗ បានសប្បាយរីករាយដោយការបោះជំរំ

ក្រុមនិស្សិតអេស្ប៉ាញបានបង្កើតជាកម្មវិធីមួយដែលមានឈ្មោះថា សាមមឺ ខេម (Summer Camp) ដែលនេះមានន័យថា ការបោះជំរំក្នុងរដូវក្តៅរបស់និស្សិតអឺរ៉ុបនាពេលសម្រាកពីការសិក្សា។ កម្មវិធីនេះបានប្រព្រឹត្តិទៅ កាលពីថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១១ នៅព្រះសហគមន៍កាតូលិកបាត់ដំបង។

នេះគឺជាលើកទី៥ ហើយដែលក្រុមយុវជនជនជាតិអេស្ប៉ាញបាន បង្កើតកម្មវិធីនេះឡើងនៅក្នុងព្រះសហគមន៍កាតូលិកបាត់ដំបង។ គោលបំណងក្រុមគេ គឺមកលេងជាមួយក្មេងៗក្នុងឱកាសវិសមកាលរបស់ក្រុម។ កម្មវិធីបោះជំរំក្នុងរដូវក្តៅ បានដំណើរការទៅ ចំនួន ២សប្តាហ៍ ដោយចាប់ពីថ្ងៃទី២៥ ខែកក្កដា ដល់ ថ្ងៃទី១២ ខែសីហា។ ក្នុងនោះក្រុមយុវជនអេស្ប៉ាញ គឺបានមកលេងសប្បាយជាមួយក្មេងៗ ចាប់ពីថ្ងៃចន្ទ ដល់ថ្ងៃសុក្រ។

ក្នុងកម្មវិធីមានការដឹកនាំតាមក្រុមតូចៗដោយក្រុមអារ៉ូប៉េ សមាជិកអនាថា ព្រមទាំងក្រុមរបស់យុវជនអេស្ប៉ាញ។ ទាំងអស់គ្នាលេងយ៉ាងរីករាយដោយមាននូវសម្លេងហ៊ោសប្បាយពីក្មេងៗ ប្រកបដោយសាមគ្គីរវាងគ្នាទៅវិញទៅមកជាមួយក្រុមរបស់ពួកគេ។ តាមធម្មតា ក្រុមយុវជនអេស្ប៉ាញបានបន្តឧបត្ថម្ភសិស្សក្រីក្រនៅពេលបញ្ចប់កម្មវិធីរបស់គេ ដោយពួកគេមិនគ្រាន់តែសប្បាយទេ។

**អាន ឫទ្ធីរដ្ឋ**



Photo : An Rithyrath

### ការវាយតម្លៃការងារក្រុមសន្តរុំាំងសង់ដឺប៉ូល

ក្រុមប្រឹក្សាថ្នាក់ជាតិចំនួន ១១រូប នៃក្រុមសន្តវ៉ាំងសង់ដឺប៉ូល ធ្វើការប្រជុំវាយតម្លៃលើសមិទ្ធផលការងារទៅតាមក្រុមនីមួយៗ នៅតាមភូមិភាគ ព្រះសហគមន៏ទាំងបីក្នុងរយៈពេលមួយឆ្នាំ២០១១ និងជាការពិភាក្សារកដំណោះស្រាយចំពោះក្រុមដែលកំពុងមានបញ្ហា។

កិច្ចប្រជុំនេះធ្វើឡើងកាលពីថ្ងៃទី៣០ ខែកក្កដា នៅព្រះវិហារយ៉ូសែប (ផ្សារតូច) ទីក្រុងភ្នំពេញ ដើម្បីជាការត្រៀមជាមុនសម្រាប់ការប្រជុំក្រុមប្រឹក្សាថ្នាក់ជាតិនៃក្រុមសន្តវ៉ាំងសង់ដឺប៉ូលទាំងអស់ក្នុងប្រទេសកម្ពុជាដែលនឹងត្រូវធ្វើនៅថ្ងៃទី២៤ ខែកញ្ញាខាងមុខនេះ។ **សុខន**

## ជួសជុលសាលាបឋមសិក្សាដើម្បីចូលរួមលើកម្ពស់វិស័យអប់រំនៅព្រះសហគមន៍កាតូលិកភូមិភាគកំពង់ចាម

សាលាបឋមសិក្សាមួយខ្នងស្ថិតនៅភូមិក្រឡា ឃុំក្រឡា ស្រុកកំពង់សៀម ខេត្តកំពង់ចាម ត្រូវបានជួសជុលកែលំអឱ្យមានលក្ខណៈល្អប្រសើរ កាលពីថ្ងៃទី១៧-១៩ ខែកក្កដាកន្លងទៅនេះ។

ការជួសជុលកែលំអនេះមានការលាបថ្នាំជាថ្មី ព្រមទាំងមានការបំពាក់នូវសម្ភារៈសិក្សាមួយចំនួនដូចជា សៀវភៅរឿងព្រេង និងសៀវភៅល្បែងល្បងប្រាជ្ញាជាដើម ដើម្បីផ្តល់ឱកាសឱ្យកូនសិស្សអាចរៀនងាយស្រួលរៀនសូត្រ និងពង្រីកចំណេះដឹងរបស់ពួកគេ។ ទាំងនេះជាអំណោយរបស់គ្រីស្ត-បរិស័ទនៃប្រទេសអូស្ត្រាលីតាមរយៈការសម្របសម្រួលពីព្រះសហគមន៏កម្ពុជា។

លោកផាន បូរ៉ា ដែលជាអ្នកសម្របសម្រួលនៃក្រុមជួសជុលការងារនេះ ក៏បានមានប្រសាសន៍ឱ្យដឹងដែរថា យើងបានបំពាក់នូវតុទូមួយចំនួនតូចរួចហើយ។ លោកបានបន្តថា នៅក្នុងបណ្ណាល័យសាលាបឋមសិក្សានេះសព្វថ្ងៃ មានសៀវភៅសម្រាប់ប្អូនៗកុមារអាន ត្រឹម ៩០ក្បាលប៉ុណ្ណោះ។ លោកបានបញ្ជាក់ថា ចំនួនសៀវភៅដែលបានបន្ថែមនេះគឺនៅមិនគ្រប់គ្រាន់សម្រាប់ឱ្យប្អូនៗកុមារនៅក្នុងសាលាបឋមសិក្សានេះបានអាន និងរៀនសូត្រនៅឡើយទេ។ ប៉ុន្តែទោះជាយ៉ាងណា សកម្មភាព និងទង្វើនេះ គឺជាការយកចិត្តទុកដាក់លើថ្នាលបណ្តុះបណ្តាលវិស័យអប់រំ ដែលនេះជាគោលដៅដ៏ចម្បងនៃការគិតគូរអំពីសង្គមជាតិរបស់យើង។

**សុខន**

# យុវជនខ្មែរ ៥១នាក់ ចូលរួមទិវាយុវជនពិភពលោកនៅអេស្ប៉ាញ

**ញឹប ញឿន**

យុវជនខ្មែរចំនួន ៥១នាក់ ដែលនឹងត្រូវបានធ្វើដំណើរទៅចូលរួមទិវាយុវជនពិភពលោក ឆ្នាំ២០១១ នៅទីក្រុងម៉ាឌ្រីត ប្រទេសអេស្ប៉ាញ បានធ្វើការជួបប្រជុំគ្នា នៅព្រះវិហារសន្តយ៉ូសែប (ផ្សារតូច) រាជធានីភ្នំពេញកាលពីថ្ងៃទី១១ ខែកក្កដាមុននេះ ដោយមានវត្តមាននៃលោកអភិបាលគីកេ ហ្វីការេដូ ជាអភិបាលភូមិភាគបាត់ដំបងផងដែរ។

លោកអភិបាលគីកេ មានប្រសាសន៍ថា វត្តមាននៃក្រុមផ្សេងៗដូចជាក្រុមម៉ាជីស ក្រុមអារូប៉េ និងយុវជនតំណាងភូមិភាគនីមួយៗ ដែលមានសកម្មភាពខុសៗគ្នាធ្វើឱ្យការប្រជុំនេះមានសារៈសំខាន់។ លោកអភិបាលពោលថា វាគឺជាឱកាសល្អដើម្បីឱ្យយុវជនយើងដែលបម្រុងនឹងចេញទៅចូលរួមព្រឹត្តិការណ៍ពិភពលោកមួយនេះអាចស្គាល់ និងយល់អំពីគ្នាទៅវិញទៅមក។

លោកអភិបាល ក្រើនរម្លឹកថា យើងត្រូវរៀបចំខ្លួនពីព្រោះយើងទៅទីនោះ មិនមែនដើម្បីសប្បាយប៉ុណ្ណោះទេ។ តែយើងទៅទីនោះដើម្បីតំណាងបងប្អូនខ្មែរ និងចែកចាយអំពីជីវិតប្រជាជនខ្មែរ ក៏ដូចជាជីវិតជាគ្រីស្តបរិស័ទខ្មែរ។ មួយវិញទៀត យើងទាំងអស់គ្នាត្រូវសាមគ្គីគ្នាជាព្រះសហគមន៍ ដោយយើងមិនមែនទៅទីនោះជាលក្ខណៈឯកជនទេ។ យើងត្រូវរៀបចំខ្លួនតាមរបៀបសមរម្យ និងចែកចាយសេចក្តីស្រឡាញ់។

ចំណែកឯលោកបូជាចារ្យហ្គោស្តាវ៉ូ ជាតំណាងលោកអភិបាលសម្រាប់ទទួលខុសត្រូវយុវជនខ្មែរមានប្រសាសន៍ថា ជាឱកាសដ៏វិសេសវិសាលណាស់ដែលយើងទាំងអស់គ្នា បានចូលរួមព្រឹត្តិការណ៍នៃសេចក្តីស្រឡាញ់។ លោកបានបន្តថា ព្រះជាម្ចាស់ត្រាស់ហៅយើងជាតំណាងព្រះសហគមន៍កម្ពុជាឱ្យចូលរួមក្នុងព្រឹត្តិការណ៍ពិភពលោក។ដូច្នេះយើងត្រូវមានបេសកកម្មមួយពិសេស គឺយើងត្រូវចែករំលែកបទពិសោធន៍ដែលយើងនឹងទទួលបាន នៅទីក្រុងម៉ាឌ្រីតដល់បងប្អូនដទៃៗទៀត។

លោកពយ ប៊ូរ៉ាត អ្នកត្រូវទៅចូលរួមទិវានេះបាននិយាយថា អ្វីដែលលោករំពឹងចង់បានពីទិវានេះ គឺមានគំនិតថ្មីក្នុងការដឹងនាំយុវជនយុវនារីក្នុងព្រះសហគមន៍ក្រោយពីពេលត្រឡប់មកវិញ។ ក្រៅពីនេះ លោកក៏ចង់ទទួលបានមិត្តភាពជាមួយយុវជនផ្សេងៗ ទៀតនៅជុំវិញពិភពលោក។

ចំណែកកញ្ញាប៉ុល ដាលុច មកពីក្រុមម៉ាជីស ក៏រំពឹងថា កញ្ញានឹងទទួលបានចំណេះដឹងថ្មី តាមរយៈការចែកបទពិសោធន៍ពីយុវជនប្រទេសនានា និងជាពិសេសជាងនេះ គឺកញ្ញាអាចនឹងស្គាល់អំពីជីវិត និងរបៀបរស់នៅនៃប្រទេសអេស្ប៉ាញ។

ក្រុមម៉ាជីសដែលមានសមាជិកប្រាំបួននាក់នឹងចេញដំណើរនៅថ្ងៃទី៤ ខែសីហា ដើម្បីទៅចូលរួមកម្មវិធី ដែលរៀបចំឡើងដោយក្រុមម៉ាជីស នៅទីក្រុងឡយ៉ូឡាប្រទេសអេស្ប៉ាញរហូតដល់ថ្ងៃទី១៥ ទើបបន្តទៅទីក្រុងម៉ាឌ្រីត ដើម្បីចូលរួមក្នុងកម្មវិធីទិវាយុវជនពិភពលោក។ ចំណែកក្រុមតំណាងភូមិភាគនឹងចេញពីប្រទេសកម្ពុជា នៅថ្ងៃទី៩ ខែសីហា ឆ្ពោះទៅប្រទេសអ៊ីតាលី ដើម្បីធ្វើទស្សនកិច្ចទីក្រុងរ៉ូម និងអាស៊ីស៊ី ហើយនៅថ្ងៃទី១៤ ទើបចេញទៅទីក្រុងម៉ាឌ្រីត ប្រទេសអេស្ប៉ាញ។

សម្រាប់កម្មវិធីទិវាយុវជនពិភពលោកនោះដែរ លោកអភិបាលគីកេ ហ្វីការេដូ នឹងឡើងចែកចាយ និងផ្តល់សក្ខីភាពអំពីជំនឿ និងវប្បធម៌នៃប្រទេសកម្ពុជានាពេលនោះ។ លោកក៏នឹងនាំជនពិការមកពីមណ្ឌលអារូប៉េ នៅបាត់ដំបងមួយចំនួន និងក្រុមរបាំដើម្បីធ្វើការបង្ហាញខ្លួន ក្នុងគោលបំណងចង់ឱ្យយុវជននៅលើពិភពលោកបានស្គាល់អំពីវប្បធម៌ខ្មែរ និងជាពិសេស ឱ្យពួកគេយល់ថា ជនពិការ និងមនុស្សមានរាងកាយល្អ ចេះរួបរួមគ្នា ហើយលើកតម្កើងព្រះជាម្ចាស់តាមរយៈវប្បធម៌។


Photo : CWYD

# បងស្រីថា : “នេះជាអំណោយសប្បាយដែលព្រះជាម្ចាស់ទ្រង់ប្រទានឱ្យខ្ញុំ”

**អ៊ឹម សុខន**



Photo : V. Sambath

បងស្រីអាញ៉ៀស ង្វៀន ដែលមានស្រុកកំនើតនៅខេត្តកណ្តាល មានក្រុមគ្រួសារជាកសិករ ។ បងស្រីមានបងប្អូន៥នាក់ និងជាកូនច្បងក្នុងគ្រួសារ ។ បងស្រីបានចូលរៀនបួសតាំងពីឆ្នាំ១៩៦២ នៃក្រុមគ្រួសារបងស្រីឧបការគុណ ។

បងស្រីរំឭកពីការត្រាស់ហៅរបស់ព្រះជាម្ចាស់ថា នៅវ័យ ១៦ឆ្នាំ ខណៈដែលបងស្រី និងមិត្តស្រីឯទៀតកំពុងជិះកង់ដើរលេង ។ ពេលនោះ ច្រវ៉ាក់កង់របស់ស្រីក៏ដាច់នៅត្រឹមមុខព្រះវិហារ ។ បងស្រីបានឈប់ និងចូលទៅសម្រាកនៅក្នុងវិហារ ហើយគំនិត ដែលចង់បួសនោះ ក៏ចាប់មានប្រាកដនៅក្នុងចិត្ត ។ ក្នុងនាមជាកូនច្បង ដូច្នេះឳពុកម្តាយមិនបានយល់ព្រមឱ្យបងស្រីទៅបួសនោះឡើយ ។ប៉ុន្តែមានម្តាយមីងម្នាក់ដែលគាំទ្របងស្រី និងនាំបងស្រីទៅកន្លែងបងស្រីឧបការគុណដែលស្ថិតនៅក្បែរស្ពានជ្រោយចង្វារនៅរាជធានីភ្នំពេញកាលពីដើម ។

សព្វថ្ងៃបងស្រីអាញ៉ៀស ង្វៀន មានតួនាទីធ្វើជាប្រធានក្រុមនៃក្រុមបងស្រីឧបការគុណ ហើយក៏ជាគណៈកម្មការនៃគ្រូអប់រំជំនឿនៅព្រះវិហារព្រះកុមារយេស៊ូ ( បឹងទំពុន) រាជធានីភ្នំពេញ ។ ក្រៅពីកិច្ចការដែលរូបបងស្រីទទួលត្រូវខាងលើនេះ បងស្រីមានភារកិច្ចមើលការខុសត្រូវកន្លែងស្នាក់អា-ស្រ័យ និងសិក្សារបស់យុវនារីដែលកំពុងតែសិក្សាដើម្បីបញ្ចប់ត្រឹមថ្នាក់ទី ១២ ផងដែរ ។ បងស្រីអាញ៉ៀស ង្វៀន និយាយដូច្នេះទៀតថា ភារកិច្ចទទួលខុសត្រូវចំពោះការងារទាំងប៉ុន្មាននេះ គឺវាមិនធ្ងន់សម្រាប់បងស្រីឡើយ ដ្បិតថា រូបស្រីមានក្តីអំណរដែលព្រះជាម្ចាស់បានជ្រើសរូបស្រីឱ្យបំពេញនូវកិច្ចការរបស់ព្រះអង្គក្នុងនាមជាបុត្រធីតា ។ ដោយឡែកអ្វីៗពិតជាងគេនោះ គឺការធ្វើសេចក្តីសម្រេចចិត្តចំពោះរឿងរ៉ាវអ្វីមួយ ដែលនេះជានិច្ចជាកាលជាភាពតានតឹងក្នុងចិត្តរបស់បងស្រី ។ទោះជាយ៉ាងណា បងស្រីបានព្យាយាមដោះស្រាយនូវបញ្ហាទាំងនេះ ដោយការអធិដ្ឋានទៅព្រះជាម្ចាស់ដើម្បីឱ្យទ្រង់ជួយបំភ្លឺរាល់ជំហានដែលបងស្រីត្រូវដើរ និងជ្រើសរើសនាពេលបន្ទាប់ ។

នៅក្នុងសេចក្តីនេះ រូបបងស្រីក៏រំពឹងផងដែរថា នៅពេលខាងមុខនឹងមានយុវនារីចេះចាប់អារម្មណ៍លើការត្រាស់ហៅរបស់ព្រះជាម្ចាស់ ដែលជាមាគ៌ានាំឱ្យយើងក្លាយទៅជាអ្នកបម្រើបងប្អូនឯងទៀត ដូចជា ព្រះយេស៊ូជាគំរូសម្រាប់រូបយើង ។

នាសព្វថ្ងៃនេះ ក្រុមគ្រួសារបងស្រីឧបការគុណមានសមាជិក ១៣នាក់ ដែលក្នុងនោះ គឺមានអ្នកដែលកំពុងស្វែងយល់ចំនួន ៤រូប និង ជាសាមណេរជានារីចំនួន ១រូប ទៀតផងដែរ ។

## គ្រីស្តបរិស័ទរួមគ្នាអធិដ្ឋានសម្រាប់អតីតសាសនទូត



Photo :L.Sovanna

ចាស់ទុំគ្រីស្តបរិស័ទកាតូលិកនៃព្រះសហគមន៍ព្រែកស្បូវ ខេត្តកំពង់ធំ បានផ្តួចផ្តើមគំនិតប្រមែប្រមូលថវិកាពីគ្រីស្តបរិស័ទ និងអ្នកស្មគ្រចិត្តក្នុងភូមិដើម្បីទិញនំចំណីផ្លែឈើ កាលពីថ្ងៃទី២៤ ខែកក្កដា មុននេះ ដើម្បីរៀបចំពិធីអធិដ្ឋានពិសេសសម្រាប់លោកចាស់ជរា ដែលចូលនិវត្តន៍ គឺលោកបូជាចារ្យរ៉ែងឌីណូ និងលោកបូជាចារ្យរ៉ូប៊ែរ វីណេ។ ថវិកាដែលនៅសល់ត្រូវដាក់តម្កល់ជាប្រាក់ដង្វាយសម្រាប់ប្រើក្នុងព្រះសហគមន៍។

ចាស់ទុំមួយរូប បានមានប្រសាសន៍ យើងជួបជុំគ្នាអង្វរព្រះជាម្ចាស់សម្រាប់លោកទាំងពីរនោះ ជាពិសេសសម្រាប់លោកតារ៉ូប៊ែរ វីណេ ដែលមានសុខភាពកាន់តែខ្សោយទៅៗ។ យើងអធិដ្ឋានសូមព្រះជាម្ចាស់ប្រទានកម្លាំងដល់លោកអាចទ្រាំទ្រនូវការឈឺចាប់ទាំងប៉ុន្មាន។ យើងអរព្រះគុណព្រះជាម្ចាស់ ដោយសារលោកតារ៉ូប៊ែរ វីណេ ទើបយើងខ្ញុំស្គាល់ព្រះជាម្ចាស់។ លោកណែនាំយើងទាំងចំណេះដឹង និងជំនឿ។ លោកជួយជីវភាពយើងមិនឱ្យអត់ឃ្លាន។ លោកតាវ័យ ៨០ឆ្នាំរូបនេះបន្ថែមថា ទោះបីលោកនៅឆ្ងាយ តែយើងជឿពិតថា ការអធិដ្ឋានរបស់យើងនឹងដល់លោកតា។

លោកបូជាចារ្យរ៉ូប៊ែរ វីណេ កើតនៅឆ្នាំ១៩១៧ លោកទទួលអគ្គសញ្ញាតែងតាំងជាបូជាចារ្យនៅឆ្នាំ ១៩៤៤ ក្នុងក្រុមសាសនទូតក្រៅប្រទេសនាទីក្រុងប៉ារីស។ លោកទៅដល់ព្រះសហគមន៍កាតូលិកកំពង់គោនៅឆ្នាំ ១៩៤៨ រហូតនៅទសវត្សទី៧០ ទើបត្រូវបណ្តេញចេញពីប្រទេសដោយពួកខ្មែរក្រហម។ នៅឆ្នាំ១៩៩២ លោកចូលមកកម្ពុជាវិញ។ លោកចូលនិវត្តន៍នៅឆ្នាំ២០០២។ ក្នុងវ័យជរាស្ថិតក្រោមការថែទាំរបស់ក្រុមសាសនទូតក្រៅប្រទេសនាក្រុងប៉ារីស លោកបានចាកចេញពីកម្ពុជាតាំងពីឆ្នាំ២០០៩។

**សុវណ្ណា**

# សមុទ្រចិនខាងត្បូងនៅចំកណ្តាលនៃជម្លោះដែនដីរវាងប្រជាជាតិជាច្រើន

**ជាត សំភី**

សមុទ្រចិនខាងត្បូងបានក្លាយទៅជាប្រធានបទពិភាក្សាយ៉ាងក្តៅគគុកមួយក្នុងរយៈពេលប៉ុន្មានខែចុងក្រោយនេះ សម្រាប់ទំនាក់ទំនងអន្តរជាតិក្រោយពីមានការប៉ះទង្គិចដោយយោធា និងការសំញែងកម្លាំងទ័ពរវាងប្រទេសចិននិងប្រទេសមួយចំនួននៅតំបន់អាស៊ីអាគ្នេយ៍។

តើហេតុអ្វីបានជាតំបន់នេះកំពុងក្លាយជាគោលដៅប្រទាញប្រទង់ និងការទាមទារជាកម្មសិទ្ធិទាំងស្រុង ឬដោយផ្ទៃករវាងមហាអំណាចពិភពលោកមួយ គឺប្រទេសចិន ជាមួយនិងបណ្តាប្រទេសមួយចំនួននៅតំបន់អាស៊ីអាគ្នេយ៍ ?



Photos : DR

ស្ព្រែតលី(Spratley) និងប៉ារ៉ាសែល (Paracel) គឺជាប្រជុំកោះពីរយ៉ាងសំខាន់នៅក្នុងសមុទ្រចិនខាងត្បូងដែលជាកម្មវត្ថុនៃជម្លោះទឹកដីដ៏ស្មុគស្មាញរវាងប្រទេសចិន កោះតៃវ៉ាន់ វៀតណាម ហ្វីលីពីន ម៉ាឡេស៊ីនិងប្រ៊ុយណេ។ ផលប្រយោជន៍នៃប្រជាជាតិផ្សេងៗគ្នាជាការទាមទារដើម្បីធ្វើការនេសាទនៅលើសមុទ្រ និងតំបន់ប្រជុំកោះទាំងពីរនេះ សិទ្ធិដើម្បីស្វែងរុករក និងការធ្វើអាជីវកម្មកំណប់ប្រេងកាត និងឧស្ម័នធម្មជាតិ និងការច្បាមយកទីតាំង និងផ្លូវសមុទ្រជាយុទ្ធសាស្ត្រ។

ការប្រមើលមើលចំពោះតំបន់ដែលសម្បូរទៅដោយផលត្រីសម្រាប់ធ្វើការនេសាទ ជាកត្តាជំរុញមួយលើការទាមទារ។

កាលពីឆ្នាំ១៩៦៨ ក៏មានការវាយតម្លៃជាលើកដំបូងដែលបង្ហាញថា តំបន់សមុទ្រចិនខាងត្បូងនេះមានភាពស្តុកស្តម្ភទៅដោយប្រេងកាត។ បើតាមមន្ត្រីប្រទេសចិនសក្តានុពលប្រេងនៅនៅក្នុងតំបន់គឺមានរហូតដល់ ១៧,៧ កោដិតោន។

ប្រទេសចិនបានធ្វើការប៉ាន់ប្រមាណថា តម្លៃនៃការធ្វើនេសាទ និងការធ្វើអាជីវកម្មប្រេងកាត នៅតំបន់សមុទ្រចិនខាងត្បូងនេះ នឹងអាចកើនឡើងដល់រាប់ពាន់កោដិដុល្លារ។

តំបន់សមុទ្រចិនខាងត្បូងនេះ គឺជាទីតាំងយុទ្ធសាស្ត្រយោធាមួយនៅអាស៊ីប៉ាស៊ីហ្វិក។ មិនត្រឹមតែប៉ុណ្ណោះ នេះគឺជាច្រកផ្លូវទឹកមួយ យ៉ាងសំខាន់ និងមមាញឹកមួយនៅលើពិភពលោក។ សព្វថ្ងៃនេះ គឺច្រើនជាងពាក់កណ្តាលនៃប្រេង ដែលដឹកជញ្ជូនតាមផ្លូវសមុទ្រ ឆ្លងកាត់សមុទ្រចិនខាងត្បូងនេះ។

ដោយសារសារៈប្រយោជន៍ខាងធនធានធម្មជាតិ និងភាពជាយុទ្ធសាស្ត្រនៃតំបន់នេះ ទើបមានការប៉ះទង្គិច និងការប្រយុទ្ធគ្នាជាច្រើនដងពីបណ្តាប្រទេសផ្សេងៗ ដែលទាមទារប្រជុំកោះ និងកម្មសិទ្ធិនៅសមុទ្រចិនខាងត្បូងនេះ។

នៅឆ្នាំ១៩៨៨ ប្រទេសចិន និងប្រទេសវៀតណាម បានប្រឈមមុខដាក់គ្នាដើម្បីធ្វើជាម្ចាស់លើជួរថ្មប៉ប្រះទឹក ចនសុន នៅប្រជុំកោះស្ព្រែតលី។

ការប្រយុទ្ធគ្នាមួយទៀតបានកើតឡើង នាដើមឆ្នាំ១៩៩៥ នៅពេលដែលប្រទេសហ្វីលីពីនបានរកឃើញនូវសំណង់យោធារបស់ចិន ដែលស្ថាបនានៅតំបន់ថ្មប៉ប្រះទឹក មីសឈីហ្វ ហើយប្រទេសហ្វីលីពីន ក៏បានធ្វើការតវ៉ាជាផ្លូវការ។

ទោះជាយ៉ាងណា ទន្ទឹមនឹងការប្រយុទ្ធគ្នា ការផ្តាច់ និងភ្ជាប់ទំនាក់ទំនងការទូតឡើងវិញជាច្រើនសារវាងប្រទេសនានាដែលទាមទារនូវកម្មសិទ្ធិលើតំបន់នេះ កិច្ចចរចាក៏ត្រូវបានធ្វើជារឿយៗផងដែរ ដែលសំខាន់ គឺការចរចារវាងប្រទេសចិន និងបណ្តាប្រទេសនៅអាស៊ីអាគ្នេយ៍។ ការចរចានឹងមានការឈានដល់កិច្ចព្រមព្រៀងគ្នា។ តែមានការរំលោភលើកិច្ចព្រមព្រៀងរវាងប្រទេសពាក់ព័ន្ធផងដែរ។

ថ្មីៗនេះ កាលពីថ្ងៃទី២០ កក្កដា នៅកោះបាលីប្រទេសឥណ្ឌូនេស៊ី នៅក្នុងកិច្ចប្រជុំប្រចាំឆ្នាំ រដ្ឋមន្ត្រីការបរទេសប្រទេសចិន និងបណ្តាលប្រទេសទាំង១០របស់អាស៊ាន ក៏បានបង្កើតដំណើរការដ៏ល្អមួយដើម្បីដោះស្រាយបញ្ហានៅតំបន់សមុទ្រចិនខាងត្បូង។ ភាគីទាំងពីរបានសម្រេចដោះស្រាយបញ្ហានេះតាមផ្លូវការទូត ដោយជៀសវាងការប្រើប្រាស់កម្លាំងបាយ ដែលវាអាចនាំឱ្យកើតមានអស្ថិរភាពនៅក្នុងតំបន់ និងពិភពលោក។



### សមុទ្រចិនខាងត្បូង

សមុទ្រចិនខាងត្បូងគឺជាផ្នែកនៃមហាសមុទ្រប៉ាស៊ីហ្វិក ដែលគ្របដណ្តប់លើផ្ទៃប្រមាណ ៣៥០០០០០គម² ដែលសណ្តូកពីប្រទេសសិង្ហបុរីទៅដល់កោះតៃវ៉ាន់។ សមុទ្រនេះមានកោះតូចៗ ដែលប្រមូលផ្តុំជាប្រជុំកោះនានា។

រដ្ឋ និងដែនដីនានានៅច្រាំងនៃសមុទ្រចិនខាងត្បូងមានដូចជា ប្រទេសចិន ដែនដីម៉ាកាវ ហុងកុង តៃវ៉ាន់ ហ្វីលីពីន ម៉ាឡេស៊ី ប្រ៊ុយណេ ឥណ្ឌូនេស៊ី សិង្ហបុរី ថៃ កម្ពុជា និងវៀតណាម។

លោកជីនី ឡាំបេង អ្នកជំនាញ ខាងអាស៊ីបូព៌ា និងអាស៊ីអាគ្នេយ៍ បានមើលឃើញសមុទ្រចិនខាងត្បូងដូចជា សមុទ្រមេឌីទែរ៉ាណេនៅចុងបូព៌ា ដែលកន្លែងនៃការផ្លាស់ប្តូរពាណិជ្ជកម្ម និងវប្បធម៌រវាងបណ្តាលប្រទេស ដែលស្ថិតនៅតាមច្រាំង ប្តូរវប្បធម៌ចិន ឥណ្ឌូនេស៊ី និងឥណ្ឌា។



Photo : S. Philong

# ល្ខោនបាសាក់កំពុងតែមានប្រជាប្រិយភាពឡើងវិញជាបណ្តើរៗ

**ជាត សំភី**

"ល្ខោនបាសាក់នាពេលសព្វថ្ងៃមានការគាំទ្រពីមហាជនឡើងវិញហើយ"។ នេះបើតាមប្រសាសន៍របស់អ្នកជំនាញសិល្បៈ និងក៏ជាតួឯកល្ខោនដ៏ល្បីមួយរូបផងដែរ។

លោកគង់ ស៊ីថន ដែលគេតែងស្គាល់ថាលោកសារ៉ន ទទួលបន្ទុកប្រធានការិយាល័យសិល្បៈនៅខេត្តកណ្តាល និងជាតួឯកល្ខោនផងដែរបានមានប្រសាសន៍ថា ល្ខោនបាសាក់មានភាពរីកចម្រើនជាងមុនបន្ទាប់ពីការបាត់ស្រមោលមួយរយៈ ចន្លោះពីឆ្នាំ១៩៨៩ ដល់ឆ្នាំ១៩៩៥ គឺនៅពេលដែលវីដេអូរឿងចិនវាយលុកចូលមក នៅក្នុងសង្គមខ្មែរ។ ប៉ុន្តែចាប់ពីឆ្នាំ២០០៣ ល្ខោនបាសាក់មានសន្ទុះ និងការនិយមបណ្តើរៗឡើងវិញពីសំណាក់មហាជន។ លោកគង់ ស៊ីថន បញ្ជាក់ថា នេះប្រហែលជាប្រជាជនដែលនិយមមើលរឿងចិន នៅពេលសម្បូរពេក គាត់ក៏ងាកមករកសិល្បៈល្ខោនវិញ។

លោកគង់ ស៊ីថន អះអាងផងដែរថា ល្ខោនបាសាក់មានប្រជាប្រិយភាព នៅតាមកម្មវិធីបុណ្យនៅវត្តនានាដូចជាបុណ្យបញ្ចុះសីមា ឬបុណ្យផ្សេងៗ ពោលគឺនៅពេល ដែលអ្នករៀបចំចង់ឱ្យកម្មវិធីបុណ្យមានភាពអធឹកអធម គាត់ហៅក្រុមល្ខោនឱ្យទៅសម្តែងចែកប្រជាជនមើល។

តាមប្រសាសន៍របស់លោកគង់ ស៊ីថន ដើម្បីឱ្យរឿងល្ខោន អាចទាក់ទាញទស្សនិកជនបាន ទាល់តែមានការគួបផ្សំគ្នារវាងការដឹកនាំរឿង និងការសម្តែង។ សម្រាប់ការដឹកនាំរឿង គឺត្រូវតែមានសាច់រឿងល្អដើម្បីទាក់ទាញទស្សនិកជន។ ចំណែកឯតួសម្តែង ក៏ត្រូវចេះសម្តែងឱ្យបានត្រឹមត្រូវដោយតម្រូវឱ្យ ពួកគាត់មាននូវការបណ្តុះបណ្តាលជាដើម។ ការសម្តែងទៀតសោតត្រូវតែមានការច្នៃប្រឌិត និងចេះប្រើប្រាស់បច្ចេកទេស គួបផ្សំក្នុងកាយវិការផ្សេងៗ ដូចជាការថ្លែងស និងប្រើធ្មសិល្ប៍ជាដើម។ លោកគង់ ស៊ីថន មានប្រសាសន៍ផងដែរថា តួសម្តែងល្ខោនបាសាក់តែងតែមាននូវការលំបាកខាងជីវភាព។ តួសម្តែងល្ខោនមួយយប់ទទួលក្លីសម្រាប់តួឯកធំ គឺទទួលបានតែត្រឹមប្រហែល ២៥ដុល្លារ។ ចំណែកឯតួធម្មតា គឺបានត្រឹម ១០ដុល្លារប៉ុណ្ណឹង។

ពាក់ព័ន្ធនឹងក្រុមកំប្លែង ដែលតែងយករឿងល្ខោនទៅសម្តែង ជាឆាកឆុតកំប្លែង បើតាមលោកគង់ ស៊ីថនបានឱ្យដឹងថា នេះគឺជាកាលៈទេសៈទេ ដែលជំរុញឱ្យគាត់ធ្វើអ៊ីចឹង គឺដើម្បីទាក់ទាញទស្សនិកជន។

លោកគង់ សុថន បានបញ្ជាក់ទៀតថា៖ "ល្ខោនបាសាក់ដែលមានកិត្តិយសឡើងវិញ ដោយសារទស្សនិកជនគាំទ្រ។ ដូច្នេះសូមពួកគាត់បន្តគាំទ្រតទៅទៀតដើម្បីកុំឱ្យទម្រង់សិល្បៈខ្មែរមួយនេះបាត់បង់"។



## រឿងកូនពស់ចង់ទិញស្បែកជើង




កូនពស់មួយមានប្រាក់១០០រៀល។ គេចង់មានស្បែកជើងពាក់នឹងគេ តែគេមិនដឹងថា ស្បែកជើងមួយថ្លៃប៉ុន្មាន។ ដូច្នេះគេក៏ដើរសួរ អ្នកដទៃទៀតមានដូចជាក្តាម ពីងពាង ចង្រិត កង្កែប... ហើយទីបំផុតគេបានជួបនឹងក្មេងស្រីម្នាក់។ បន្ទាប់ពីជួបអ្នកទាំងនេះម្តងៗ កូនពស់អាចសម្គាល់ចំនួនជើងសត្វផ្សេងៗ និងចំនួនប្រាក់ដែលគេចំណាយដើម្បីទិញស្បែកជើង។ ទីបំផុតកូនពស់ដឹងហើយថា គេត្រូវការប្រាក់ប៉ុន្មានដើម្បីទិញស្បែកជើងសម្រាប់ខ្លួនគេ! កូនពស់ចង់ទិញស្បែកជើង គឺជារឿងអាល់ប៊ុម សម្រាប់កុមារ។

រឿងនេះសរសេរឡើងស្របតាមកម្មវិធីសិក្សាថ្នាក់ទីពីរ ផ្នែកគណិតវិទ្យានៅសាលាបឋមសិក្សា។ កុមារអាចរៀនគិតលេខតាមវិធីសាមញ្ញតាមរយៈសាច់រឿងងាយអានដែលលម្អដោយរូបភាពវិចិត្រដែលជាទីទាក់ទាញ។

រឿងនេះនិពន្ធដោយស្រ៊ុន ទ្រី រចនារូបដោយយ៉ូម កុសល បោះពុម្ពនៅឆ្នាំ២០១០ ដោយអង្គការហ្វូមធ្វីដ។

## ឡាក់គីលុច១៦ដំណើរតាមទន្លេមីស៊ីស៊ីពី



ចំពោះប្អូនៗ យុវជនដែលចូលចិត្តអានសៀវភៅគំនូររូបភាព (សៀវភៅតុក្កតា) គ្មានជម្រើសណាល្អដូចក្រុមសៀវភៅឡាក់គី លុច នេះឡើយ! មិនត្រឹមតែក្រមិចក្រមើម កំប្លែង ពូកែបាញ់កាំភ្លើង និងក្លាហានប៉ុណ្ណោះទេ តែលោកឡាក់គី លុច ជាមនុស្សប្រកាន់សច្ចធម៌ ដូចជាជួយជនស្លូតត្រង់ប្រឆាំងនឹងពួកជនអន្ធពាល។ នៅក្នុងគ្រប់ដំណើរផ្សងផ្សេងរបស់ខ្ញុំ ប៊យរូបនេះគាត់មានបេសកកម្មពិសេសមួយជានិច្ច។

តួយ៉ាងនៅក្នុងរឿងដំណើរឡើងតាមទន្លេមីស៊ីស៊ីពី លោកឡាក់គី លុច ចូលរួមជាមួយលោកកាពីទែនបារ៉ូវ ដើម្បីបើកកប៉ាល់ប្រកួតប្រជែងគ្នាជាមួយកាពីទែនសម្បូរល្បិច ឈ្មោះឡូវីវែរ។ រង្វាន់ដ៏ធំនៃការប្រកួតនេះ គឺសិទ្ធិធ្វើនាវាចរណ៍ផ្តាច់មុខលើទន្លេមីស៊ីស៊ីពី។ ម្តងជាពីរដង! ឡូវីវែរតែងតែរកល្បិចកលបន្ទុចបន្ទាក់ដំណើររបស់កប៉ាល់ម្ខាងទៀត។ ប៉ុន្តែខូវប៊យរូបក្មេងយើងមិនដែលប្រហែសមួយវិនាទីឡើយ!

ច្បាប់ដើមមានចំណងជើងថា (En remontant le Mississippi) និពន្ធដោយលោក ម៉ូរីស និងហ្គូស៊ីនី ដែលត្រូវបានបកប្រែជាភាសាខ្មែរដោយស៊ិន សុធា។ រឿងនេះបោះពុម្ពនៅឆ្នាំ២០០៨ ដោយគ្រឹះស្ថានបោះពុម្ពផ្សាយមេគង្គ។

**ហួត សុជាតា**

# អធិប្បាយព្រះបន្ទូលថ្ងៃអាទិត្យ



**ខែសីហា ២០១១ ដោយលោកដួង សាវឌ្ឍ ប្រធានមណ្ឌលអប់រំជំនឿព្រះសហគមន៍កាតូលិកម្ពុជា**

***ថ្ងៃអាទិត្យទី១៩ ក្នុងរដូវធម្មតា ត្រូវនឹងថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១១ (ម៉ាថាយ ១៤:២២-៣៣)***

អត្ថបទថ្ងៃនេះ ពួកគ្រីស្តទូតមានបទពិសោធន៍យ៉ាងច្រើនអំពីព្រះយេស៊ូស្រឡាញ់ពួកគាត់។ ពេលជួបព្យុះ ព្រះអង្គយាងទៅរកពួកគាត់ភ្លាម ហើយពេលពួកគាត់ភ័យខ្លាចដោយស្មានថាព្រះអង្គជាខ្មោច ព្រះអង្គក៏មានព្រះបន្ទូលទៅពួកគាត់ ដើម្បីឱ្យមានចិត្តនឹងនរិញ។ ពេលលោកសិលាលិចក្នុងទឹកស្រែកអង្វរព្រះអង្គ ព្រះអង្គក៏លូកព្រះហត្ថទៅរកគាត់ភ្លាមដែរ ហើយពេលព្រះអង្គគង់នៅក្នុងទូកជាមួយពួកគាត់ ស្រាប់តែខ្យល់ក៏ស្ងប់ទៅ។ សព្វថ្ងៃ ព្រះយេស៊ូក៏ស្រឡាញ់យើងដែរ ព្រះអង្គការពារយើងពីគ្រោះថ្នាក់។ ព្រះអង្គលើកទឹកចិត្តយើងពេលយើងជួបឧបសគ្គ។ ព្រះអង្គក៏ជំរុញយើងឱ្យធ្វើតែកិច្ចការដែលគាប់ព្រះហឫទ័យព្រះអង្គដែរ... ចូរយើង បើកចិត្តទទួលព្រះអង្គ ដែលយាងមករកយើងជារៀងរាល់ថ្ងៃ។

***អាទិត្យទី២០ ក្នុងរដូវធម្មតា ត្រូវនឹងថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១១***
***(ម៉ាថាយ ១៥:២១-២៨)***

អត្ថបទថ្ងៃនេះ នាំយើងឱ្យចាប់អារម្មណ៍អំពីជំនឿដ៏រឹងមាំរបស់ស្ត្រីជាតិកាណានម្នាក់ ដែលមានចិត្តសុភាពរាបសា ស៊ូទ្រាំនឹងព្រះបន្ទូលសាកល្បងរបស់ព្រះយេស៊ូចំពោះគាត់។ ទីបំផុតដោយសារជំនឿមិនងាករេ គឺគាត់ផ្ញើជីវិតទាំងស្រុងលើព្រះយេស៊ូ នោះកូនរបស់គាត់ក៏បានសះស្បើយភ្លាម។ ពិតមែនហើយដោយសារជំនឿ នាំឱ្យយើងចេះបន្ទាបខ្លួន មានចិត្តរាបសា ចិត្តស៊ូទ្រាំ ហើយព្រះអង្គក៏នឹងឆ្លើយតបមកយើងតាមព្រះអង្គសព្វព្រះហឫទ័យដែរ។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយអ្នកជឿត្រូវតែយល់ឱ្យច្បាស់ថា ព្រះជាម្ចាស់មិនតបឆ្លើយតាមបំណងយើងគ្រប់ពេលទេ ព្រោះព្រះអង្គសព្វព្រះហឫទ័យឱ្យយើងរីកចម្រើនខាងវិញ្ញាណ គឺឱ្យយើងផ្ញើជីវិតទាំងស្រុងលើព្រះអង្គដែលស្រឡាញ់ខ្លួន ក្នុងគ្រប់កាលៈទេសៈ។

***អាទិត្យទី២១ ក្នុងរដូវធម្មតា ត្រូវនឹងថ្ងៃទី២១ ខែសីហា ឆ្នាំ២០១១***
***(ម៉ាថាយ ១៦:១៣-២០)***

អត្ថបទថ្ងៃនេះ មានលោកសិលាជាតួសំខាន់ ដ្បិតព្រះយេស៊ូបានជ្រើសរើសគាត់ឱ្យទៅជាគង្វាលលើហ្វូងចៀមរបស់ព្រះអង្គ។ លោកសិលាមានលក្ខណៈពិសេសម្យ៉ាង គឺគាត់ជាមនុស្សរឹងប៉ឹង ជាអ្នកដែលហ៊ានសួរនិងហ៊ានឆ្លើយឆ្លងជាមួយនិងព្រះយេស៊ូ ក្នុងនាមគ្រីស្តទូតទាំង១២។ តែពេលខ្លះទៀតគាត់ក៏ជាមនុស្សកំសាកដែរ។ តាមពិត គាត់មិនមែនជាមនុស្សល្អអត់ខ្ចោះនោះទេ។ ព្រះយេស៊ូជ្រើសរើសគាត់ តាមព្រះអង្គសព្វព្រះហឫទ័យប៉ុណ្ណោះ ព្រះអង្គលើកលែងទោសឱ្យគាត់ និងស្រឡាញ់គាត់តទៅទៀត។ ពេលលោកសិលាដឹងថា ព្រះយេស៊ូនៅតែស្រឡាញ់គាត់ គាត់ប្រែចិត្តផ្ញើជីវិតទាំងស្រុងលើព្រះអង្គ ហើយគាត់ក៏ចង់ចែកសេចក្តីស្រឡាញ់នោះដល់អ្នកឯទៀតៗដែរ។ សព្វថ្ងៃ ក្នុងព្រះសហគមន៍ សម្តេចប៉ាបជាអ្នកបន្តមុខងារពីលោកសិលា។

***អាទិត្យទី២២ ក្នុងរដូវធម្មតា ត្រូវនឹងថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១១***
***(ម៉ាថាយ ១៦:១៣-២០)***

អត្ថបទថ្ងៃនេះ លោកសិលានៅតែជាតួអង្គដ៏សំខាន់ដដែល។ ថ្ងៃអាទិត្យមុន ព្រះយេស៊ូជ្រើសរើសគាត់ទៅជាគង្វាលលើហ្វូងចៀមរបស់ព្រះអង្គ តែថ្ងៃនេះ ព្រះអង្គបន្ទោសគាត់ ហៅគាត់ថាជាសាតាំងទៅវិញ ហើយឱ្យគាត់ថយទៅនៅពីខាងក្រោយព្រះអង្គ គឺឱ្យគាត់ត្រាប់តាមព្រះអង្គដែលរងទុក្ខលំបាក និងសោយទិវង្គត។ តាមពិត លោកសិលាមិនអាចយល់ភ្លាមៗពីឋានៈជាព្រះគ្រីស្ត គឺព្រះយេស៊ូត្រូវតែរងទុក្ខលំបាក និងសោយទិវង្គតជាមុនសិននោះទេ។ ដោយហេតុនោះហើយ ទើបគាត់អង្វរព្រះជាម្ចាស់កុំឱ្យហេតុការណ៍នោះកើតឡើង។ តាមធម្មតាមនុស្សយើងមិនចង់ទទួលទុក្ខលំបាកអ្វីទេ តែព្រះយេស៊ូមានព្រះបន្ទូលថា "អ្នកណាចង់ដើរតាមខ្ញុំ ត្រូវលះបង់ខ្លួនឯងចោល លីឈើឆ្កាងរបស់ខ្លួន ហើយតាមខ្ញុំចុះ"។

## យុវវ័យជួយស្ត្រីដូចជួយខ្លួនឯង និងសង្គមជាតិ (ត) *(បទពាក្យប្រាំពីរ)*





**និពន្ធដោយ :**
**លោកស្រី ឌុង ណារី**
**ថ្ងៃទី១៩ កក្កដា ឆ្នាំ២០១១**
**រៀបរៀងដោយ :**
**លោក ឡុង សុផល**

៤១-អាវសខោខៀវរាងរាវល្អិត សមជានិស្សិតសិស្សសាលា
សំពត់សំយេះអាវប៉ោងស្មា តម្រង់សាលាថ្នាក់ឧត្តម ។

៤២-សម្លឹងមើលលើស្ទើរស្ពាក់ពេក គ្រាន់តែក្រឡេកដូចមិនសម
សក់ហាយឡាយពណ៌យ៉ាងសាណំ ក្រវិលស្មៀតធំជាប់ត្រចៀក ។

៤៣-ឯក្រចកដៃថ្ងៃបិទផ្កា ជាសិស្សសាលាទាំងសម្លៀក
ផាត់មុខក្រែមម្សៅដៅបូកបៀក តែងសក់ចងច្រៀកងាករលាស់។

៤៤-សិស្សប្រុសធ្វើខ្លួនដូចតារា សក់រ៉ែងប្រះស្នាល្អអស់ទាស
ម៉ូតូសេរីថ្មីទាំងអស់ ប្រឹងជិះបង្ហោះបង្អួតគ្នា ។

៤៥-ចាស់ព្រឹទ្ធាចារ្យដើរតាមផ្លូវ ជិះរឹងហួសទៅគ្មានវន្ទា
គំរូសិស្សល្អដ៏ពាលា ណាត់ជួបជុំគ្នាផឹកបៀលេង ។

៤៦-ប្រឹងក្រេបជញ្ជក់រសជាតិពុល សប្បាយឥតខ្វល់តាមបទភ្លេង
ខារ៉ាអូខេផ្ទេរសម្លេង សម្លឹងយ៉ាងខែងស្តែងប្រតិបត្តិ ។

៤៧-សាលាគ្មានគ្រូគួរត់រក សសុលពួនជ្រកចំណាត់
អ្វីដែលច្បាប់ឃាត់គាត់ស្វែងស្គាត់ សិក្សាសម្ងាត់ចាត់ចែងចង់ ។

៤៨-ម៉ោងរៀនគ្មានគិតពីចំណេះ ចំណង់ពិសេសចេះលិចលង់
គេចពីសាលាបរតម្រង់ តម្រាប់ដែលល្ងង់លង់អារម្មណ៍។

៤៩-ពុកម្តាយសរសើរដំណើរកូន សិក្សារលូនថ្នាក់ឧត្តម
បាត់ៗពីផ្ទះរះរូតខំ ប្រឹងរៀនកូនខ្ញុំធំពូកែ ។

៥០-មិនបានដឹងទេមាសមេស្នូន ថាកូននឹមនួនពួនគេចបែរ
ថ្នាក់រៀនឈានចាករាល់ថ្ងៃខែ យកប្រាក់ពុកម៉ែដើរស៊ីចាយ ។

# ព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ បាត់ដំបង និងកំពង់ចាម ប្រទេសកម្ពុជា

( ដោយៈ សម្បត្តិ សុវណ្ណា និងសុធារិទ្ធ )



អគ្គសញ្ញាលាបប្រេងថ្វាសនៅព្រះសហគមន៍គីរីវង្ស



លោកអភិបាលសុខកុមារ អូលីវីយេ ជ្មីតអីស្លែរ ប្រោះព្រំទឹកព្រះពរលើរូបសំណាក សន្ត យ៉ូសែប នៅព្រះវិហារសន្ត យ៉ូសែប ( ផ្សារតូច )ភ្នំពេញ។



ពិធីប្រគល់ព្រះគម្ពីរ ទទួលស្គាល់ បងប្រុសផាន បូរីជាអ្នកប្រកាសព្រះបន្ទូលព្រះជាម្ចាស់ ថ្ងៃទី០៧ សីហា, ២០១១



ពិធីបំពាក់អាវសេ ទទួលស្គាល់បងប្រុស សែ សាត ជាកូនសិស្សលោកអភិបាល ថ្ងៃទី០៧ សីហា, ២០១១



ពិធីប្រគល់ព្រះគម្ពី និងទទួលស្គាល់បងប្រុស មួង រស់ ជាអ្នកប្រកាសព្រះបន្ទូលព្រះជាម្ចាស់ ថ្ងៃទី០៧ សីហា, ២០១១



ពិធីប្រគល់ព្រះគម្ពី និងទទួលស្គាល់បងប្រុស មួង រស់ ជាអ្នកប្រកាសព្រះបន្ទូលព្រះជាម្ចាស់ ថ្ងៃទី០៧ សីហា, ២០១១



ពីធីអគ្គសញ្ញាលាបប្រេងថ្វាសនៅព្រះសហគមន៍ ឆ្នុកទ្រូ

# ព័ត៌មាន

## សិស្សដុនបូស្កូទឹកថ្លា ១០៩នាក់ ទទួលបានវិញ្ញាបនបត្រ


Photos : T.Yort

សិក្ខាកាមនាជំនាន់ទី១៧ ចំនួន ១០៩នាក់ នៅមជ្ឈមណ្ឌលបណ្ដុះបណ្ដាលវិជ្ជាជីវៈដុនបូស្កូ ទឹកថ្លា បានទទួលវិញ្ញាបនបត្រកាលពីថ្ងៃទី២៣ ខែកក្កដា កន្លងទៅ នៅក្នុងកម្មវិធីដែលមានការចូលរួមជាអធិបតីភាពពីសំណាក់ឯកឧត្តមប៉ុក ប៉ាន់ជាអនុរដ្ឋលេខាធិការក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ បងស្រីតេរេស៊ីតា តំណាងសាឡេស៊ានដុនបូស្កូប្រចាំប្រទេសកម្ពុជា និងភូមា លោកអភិបាលគីកេហ្វីការេដូ បងស្រី លោកឪពុក បុគ្គលិក និងអាណាព្យាបាលសិស្សប្រមាណ ១០០០នាក់ ។

បងស្រីអូហ្វ្រេនី អេលីហ្សាប៉ែត នាយិកាសាលាបណ្ដុះបណ្ដាលវិជ្ជាជីវៈដុនបូស្កូ (ទួលគោក) មានប្រសាសន៍ថានៅក្នុងឆ្នាំសិក្សានេះ មានសិស្សសរុបចំនួន២៦៨នាក់ បានបញ្ចប់ការសិក្សា ដែលនៅក្នុងនោះ មាន ៤៨នាក់ សិក្សាលើជំនាញកុំព្យូទ័រ និងលេខាធិការ (ទួលគោក) ៣៥នាក់ លើជំនាញវិជ្ជាមេផ្ទះ និងធ្វើម្ហូប (ទឹកថ្លា) និង២៧នាក់លើជំនាញកាត់ដេរនិងអក្ខរកម្ម (បាត់ដំបង) ។ បងស្រីក៏បានបន្តថា សិស្ស១០០% នៅឆ្នាំនេះ បានបញ្ចប់នូវការសិក្សារបស់ពួកគេដោយជោគជ័យ ហើយនៅក្នុងចំណោមនោះ ពួកគេ ៨០% បាននូវការងារធ្វើ និងទទួលបានការយកចិត្តទុកដាក់យ៉ាងខ្លាំងពីសំណាក់និយោជក អ្នកគ្រប់គ្រងតាមសណ្ឋាគារ ក្រុមហ៊ុន ធនាគារ ក្រសួង មន្ទីររដ្ឋាភិបាល ស្ថានទូត និងអង្គការផ្សេងៗ ។ ពួកគេក៏បានជួយក្រុមគ្រួសារឱ្យមានជីវភាពកាន់តែល្អប្រសើរជាងមុន ។ បងស្រីបញ្ជាក់ថាយើងធ្វើការអប់រំបុគ្គលិកលក្ខណៈ ប្រាជ្ញាស្មារតី សតិអារម្មណ៏ សីលធម៌ សង្គម និងចំណេះដឹងដើម្បីឱ្យពួកគេក្លាយជាពលរដ្ឋល្អ សកម្ម និងស្មោះត្រង់ ។

នាឱកាសនោះដែរ ឯកឧត្តមប៉ុក ប៉ាន់ អនុរដ្ឋលេខាធិការក្រសួងការងារបណ្ដុះបណ្ដាលវិជ្ជាជីវៈ បានថ្លែងអំណរគុណដល់បងស្រីតេរេស៊ីតា និងបងស្រីសាឡេស៊ានទាំងអស់ដែលបានចូលរួមបណ្ដុះបណ្ដាលសិស្សឱ្យក្លាយជាធនធានមនុស្សសំខាន់ក្នុងការអភិវឌ្ឍប្រទេសជាតិជាមួយរដ្ឋាភិបាល ។ លោកបញ្ជាក់ថា: "ការប្រគល់វិញ្ញាបនបត្រនៅថ្ងៃនេះ បានចូលរួមចំណែកអភិវឌ្ឍចំណេះដឹង ជំនាញ និងបានចូលរួមចំណែកយ៉ាងសំខាន់ក្នុងការអភិវឌ្ឍប្រទេសជាតិ តាមរយៈការបង្កើតការងារ រកប្រាក់ចំណូលផ្គត់ផ្គង់គ្រួសារ និងចូលរួមកាត់បន្ថយភាពក្រីក្រ ។

**ថុង យ៉ត**

## "ជៀសពីគ្រឿងញៀន ដើម្បីការពារជីវិតអ្នក"



## ដំណឹងស្វែងរកមនុស្ស

អង្គការមនុស្សលោកថ្មី និងឪពុកម្ដាយ
បាននិងកំពុងស្វែងរកជនពិការវិបត្តិផ្លូវចិត្តម្នាក់ ឈ្មោះប្រឹង សារ៉ាង
ភេទស្រី អាយុ ២៩ឆ្នាំ រស់នៅភូមិស្វាយព្រៃ ឃុំកណ្ដោក
ស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល។
សារ៉ាងបានរត់ចេញពីមន្ទីរពេទ្យកាល់មែត្រ កាលពីម៉ោង ប្រហែល
១០ព្រឹក នាថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១១ ពេលនាងមកពិនិត្យជំងឺ។
សារ៉ាងមានសម្បុរសណ្ដែកបាយ ស្លៀកខោគគីពណ៌គគី អាវដៃខ្លីពណ៌
អាចម៍សេះ និងពាក់ខ្សែក អំបោះឆៅមានបណ្ដោងចិញ្ចៀន។
ប្រសិនបើលោក-លោកស្រីណាបានប្រទះឃើញនាងដែលមានរូបរាងដូច
ក្នុងរូបថត សូមមេត្តាទំនាក់ទំនង មកទូរស័ព្ទលេខ :
០១៦ ៨៥៨ ៩៤៩, ០៧៧ ៣៥៥ ០០១ ឈ្មោះ ចាន់ឌី
០៩២ ៨០២ ៣១២ ឈ្មោះ សុផា។ សូមអរគុណ!

## ការងារប្រចាំខែ

- ថ្ងៃទី៥ ខែសីហា : ភ្ញៀវមកពីតៃវ៉ាន់ ១៨នាក់ ជួយបង្រៀនភាសាអង់គ្លេស និងលេងជាមួយក្មេងនៅមណ្ឌលពាក់ស្នែងថ្មី ខេត្តសៀមរាប។
- ថ្ងៃទី៥ ខែសីហា : ក្រុមវ៉ាំងសង់ដឺប៉ូល និងក្រុមយុវជនចុះទៅសួរសុខទុក្ខ និងចែកអំណោយដល់ចាស់ជរា នៅព្រះសហគមន៏អ្នកលឿង ភូមិភាគកំពង់ចាម។
- ថ្ងៃទី៦ ខែសីហា : ភ្ញៀវមកពីតៃវ៉ាន់ ១៨នាក់ ជួយបង្រៀនភាសាអង់គ្លេស និងលេងជាមួយក្មេងនៅមណ្ឌលកំពង់ឃ្លាំង ខេត្តសៀមរាប។
- ថ្ងៃទី៦ ខែសីហា : ភ្ញៀវតៃវ៉ាន់ចំនួន ១៨នាក់ ទៅសួរសុខទុក្ខ និងមានចែកអំណោយដល់អ្នកជំងឺនៅមន្ទីរពេទ្យនៅព្រះសហគមន៏សៀមរាប។
- ថ្ងៃទី៧ ខែសីហា : ភ្ញៀវតៃវ៉ាន់ចំនួន ១៣នាក់ ទៅចូលរួមអភិបូជា និងលេងជាមួយក្មេង និងមានកម្មវិធីបបរពិសេស នៅព្រះសហគមន៏ចុងឃ្នៀស ខេត្តសៀមរាប។
- ថ្ងៃទី៧ ខែសីហា : ភ្ញៀវតៃវ៉ាន់ចំនួន ១៨នាក់ ទៅចូលរួមអភិបូជា លេងជាមួយក្មេង និងមានកម្មវិធីបបរ ពិសេសនៅព្រះសហគមន៏ព្រែកទាល់ ខេត្តសៀមរាប។
- ថ្ងៃទី១១ សីហា : នៅព្រះសហគមន៏សៀមរាប មានរៀបចំកម្មវិធីប្រជុំអន្តរសាសនាក្រោមប្រធានបទ "ការដោះស្រាយទំនាស់របស់សាសនា" ដែលមានគ្រប់សាសនាចូលរួមក្នុងកម្មវិធីនេះ នៅសណ្ឋាគារសៀមរាបថោន ដែលចាប់ផ្ដើមធ្វើពីម៉ោង ៧:៣០ព្រឹក ទៅដល់ម៉ោង៥:៣០ ល្ងាច។
- ថ្ងៃទី១៥-១៧ ខែសីហា : ភ្ញៀវតៃវ៉ាន់ចំនួន ១៣នាក់ មកជួយបង្រៀនភាសាអង់គ្លេស បង្រៀនគូរគំនូរ នៅព្រះសហគមន៏កាតូលិកតាអំ ខេត្តសៀមរាប។


## ការិយាល័យព័ត៌មានកាតូលិក

ផ្ទះលេខ ២៥ ផ្លូវលេខ ២៤២ សង្កាត់
បឹងព្រលិត ខណ្ឌ ៧ មករា រាជធានី ភ្នំពេញ
Tel/Fax : (855) 23 224 120;
E-mail : csccambodia@gmail.com
Website : www.catholiccambodia.org
អ្នកសម្របសម្រួល : លោកស្រីប្រាម៉ុង
វីរជ័យ ។ ប្រធាន : លោកលី សុវណ្ណា ។
Licence ១៨៣ ពម.ប្រក. / ២៥-មិថុនា-២០០៧